# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ព្រែកត្នោត

## សម្រាប់រយៈពេល ០៣ ឆ្នាំ

## (ខែមិថុនា ឆ្នាំ ២០២០ - ខែមិថុនា ឆ្នាំ ២០២៣)

| | |
|---|---|
| សហគមន៍នេសាទ | ៖ ព្រែកត្នោត |
| ភូមិ | ៖ ព្រែកត្នោត |
| ឃុំ | ៖ ព្រែកត្នោត |
| ស្រុក | ៖ ទឹកឈូ |
| ខេត្ត | ៖ កំពត |

ថ្ងៃទី១៦ ខែមិថុនា ឆ្នាំ ២០២០

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ព្រែកត្នោត

## សម្រាប់រយៈពេល ០៣ ឆ្នាំ

(ខែមិថុនា ឆ្នាំ ២០២០ - ខែមិថុនា ឆ្នាំ ២០២៣)

| | |
|---|---|
| សហគមន៍នេសាទ | ៖ ព្រែកត្នោត |
| ភូមិ | ៖ ព្រែកត្នោត |
| ឃុំ | ៖ ព្រែកត្នោត |
| ស្រុក | ៖ ទឹកឈូ |
| ខេត្ត | ៖ កំពត |

ថ្ងៃទី១៦ ខែមិថុនា ឆ្នាំ ២០២០

# មាតិកា

**១.ស្ថានភាពទូទៅ** ........ ៤

**២.អំពីប្រជាសាស្ត្រនិងសេដ្ឋកិច្ចសង្គម** ........ ៤

ក.ប្រជាពលរដ្ឋ ........ ៤

ខ.សេដ្ឋកិច្ចសង្គម ........ ៥

**៣.កន្លែងនេសាទ និងធនធានជលផលដែលមាននៅក្នុងកន្លែងនេសាទសហគមន៍** ........ ៦

ក.ទីតាំង ........ ៦

ខ.ដែននេសាទ ........ ៦

គ.តំបន់ដែលមានលទ្ធភាពអាចបង្កើតកន្លែងអភិរក្ស ........ ៦

ឃ. ធនធានជលផល ........ ៦

១.ប្រភេទត្រី ........ ៧

២.ប្រភេទវារីសត្វ ........ ៧

៣.ប្រភេទរុក្ខជាតិព្រៃកោងកាង និងវារីរុក្ខជាតិសមុទ្រ ........ ៧

**៤.ការធ្វើនេសាទ** ........ ៧

ក.អ្នកនេសាទ ........ ៧

ខ.ឧបករណ៍នេសាទ ........ ៧

គ.ប៉ាន់ប្រមាណផលនេសាទចាប់បានប្រចាំឆ្នាំ ........ ៩

**៥.ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍** ........ ៩

ក.ទស្សនៈវិស័យ ........ ១០

ខ.គោលបំណង ........ ១០

គ.ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ........ ១០

គ.១.ផែនការប្រើប្រាស់ឧបករណ៍នេសាទ ........ ១០

គ.២.ផែនការកែលំអរដែននេសាទ ........ ១១

គ.៣.ផែនការកំណត់ និងរៀបចំកន្លែងអភិរក្ស ........ ១១

គ.៤.ផែនការគ្រប់គ្រងព្រៃកោងកាង ........ ១២

គ.៥.ផែនការអភិវឌ្ឍន៍វារីវប្បកម្ម ........ ១៣

គ.៦.ផែនការអភិវឌ្ឍន៍មុខរបរទ្រទ្រង់ជីវភាព ........ ១៤

គ.៧.ផែនការអភិវឌ្ឍន៍កន្លែងកំសាន្តរបស់សហគមន៍ ........ ១៥

គ.៨.ផែនការពង្រឹងសមត្ថភាពគណៈកម្មការសហគមន៍នេសាទ ........ ១៦
គ.៩.ផែនការផ្សព្វផ្សាយពីច្បាប់ជលផលនិងលិខិតបទដ្ឋានពាក់ព័ន្ធ ........ ១៦
គ.១០.ផែនការបង្កើតស្នាក់ការ និងបណ្ណាល័យសហគមន៍នេសាទ ........ ១៧
គ.១១. ផែនការថវិការទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍ ........ ១៧
គ.១២.ផែនការចូលរួមប្រជុំជាមួយស្ថាប័នពាក់ព័ន្ធ ........ ១៨
គ.១៣.ផែនការសុវត្ថិភាពក្នុងការនេសាទលើផ្ទៃសមុទ្រ ........ ១៨
**ឃ.យុទ្ធសាស្ត្រ** ........ ១៩
**៦.ឧបសម្ពន្ធ**
ឧបសម្ពន្ធសង្ខេប: ១.តារាងផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ឆ្នាំ ២០២០-២០២៣
២.តារាងកម្មវិធីការងារសម្រាប់សហគមន៍នេសាទព្រែកត្នោត
ក្នុងរយៈពេល ០៣ ឆ្នាំ (ខែមិថុនា ឆ្នាំ២០២០- ខែមិថុនា ឆ្នាំ ២០២៣)

# ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ព្រែកត្នោត

## ១.ស្ថានភាពទូទៅ

នៅឆ្នាំ២០០០ រដ្ឋបាលជលផលបានធ្វើកំណែទម្រង់ ដើម្បីឱ្យស្របជាមួយគោលនយោបាយវិមជ្ឈការ-វិសហមជ្ឈការ និងយុទ្ធចតុកោណរបស់រាជរដ្ឋាភិបាលដែលផ្តោតលើការកាត់បន្ថយភាពក្រីក្រដោយផ្ទេរសិទ្ធអំណាចដល់ប្រជាពលរដ្ឋដែលរស់នៅក្នុងតំបន់ជនបទ ឱ្យចូលរួមចូលរួមគ្រប់គ្រងធនធានជលផលនៅមូលដ្ឋានរបស់ខ្លួនប្រកបដោយចីរភាព និងសមធម៌តាមបែបសហគមន៍នេសាទ ក្នុងគោលបំណងទទួលផលប្រយោជន៍ និងធ្វើឱ្យធនធានជលផលឱ្យប្រសើរឡើងក្នុងមូលដ្ឋានរបស់ខ្លួន។ ភូមិព្រែកត្នោត ត្រូវបានរៀបចំសហគមន៍នេសាទ ដោយមានការចូលរួមយ៉ាងកុះករពីប្រជាពលរដ្ឋមូលដ្ឋាននិងបានការគាំទ្រពីគម្រោង DFID/DANID សហការជាមួយជំនាញជលផលនិងអាជ្ញធរដែនដី ។ ដូចេនះ សហគមន៍នេសាទ ត្រូវបានបង្កើតឡើងដោយមហាសន្និបាតលើកដំបូងនៅថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០០៤ និងបានចុះកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍លើកទី១នៅថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៩ ដែលបានរៀបចំផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ដោយបានអនុវត្តចាប់ពីឆ្នាំ ២០១២ ដល់ ២០១៤ ព្រមទាំងត្រូវបានក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទប្រកាសទទួលស្គាល់នៅថ្ងៃទី១៤ខែមីនា ឆ្នាំ២០១១ ដែលមានទីតាំងស្ថិតនៅក្នុងភូមិព្រែកត្នោត ឃុំ ព្រែកត្នោត ស្រុកទឹកឈូ ខេត្តកំពត។ ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ព្រែកត្នោតនឹងធ្វើបច្ចុប្បន្នភាពលើកទី២នៅថ្ងៃទី១៧ខែមិថុនា ឆ្នាំ២០២០ ដោយមានចូលរួមពីសមាជិកនិងគណៈកម្មសហគមន៍នេសាទ មេភូមិព្រែកត្នោត និងក្រុមប្រឹក្សាព្រែកត្នោត ជាពិសេសបានការគាំទ្របច្ចេទេសពីរដ្ឋបាលជលផលថ្នាក់កណ្តាលនិងសម្របសម្រួលដោយខណ្ឌរដ្ឋបាលជលផលកំពត។

គណៈកម្មការសហគមន៍នេសាទព្រែកត្នោតមានចំនួន០៩នាក់ ស្រី ០នាក់ ហើយបានអនុវត្តភារៈកិច្ចរបស់ខ្លួនដែលស្របតាមលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង ផែនទីព្រំប្រទល់កន្លែងនេសាទសហគមន៍និងកិច្ចព្រមព្រៀងកន្លែងនេសាទ។ ទន្ទឹមនឹងនេះ គណៈកម្មសហគមន៍នេសាទ ត្រូវបានកសាងសមត្ថភាពតាមរយៈការចូលរួមបណ្តុះបណ្តាល សិក្ខាសាលា ប្រជុំបណ្តាញការងារនិងទស្សនកិច្ចសិក្សានិងរៀនសូត្រតាមឯកសារផ្សេងៗ។

ដូច្នេះ ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ បានធ្វើការកែសម្រួលសកម្មភាពសំខាន់ៗខ្លះនិងថវិកាដែលគ្រោង ដើម្បីអាចធានាដល់ការគ្រប់គ្រងធនធានជលផលនៅក្នុងកន្លែងអភិរក្សសហគមន៍ ព្រមទាំងប្រជាពលរដ្ឋមូលដ្ឋានទទួលបានផលប្រយោជន៍ពីធនធានជលផលប្រកបដោយចីរភាព និងសមធម៌។

## ២.អំពីប្រជាសាស្ត្រ និង សេដ្ឋកិច្ចសង្គម

### ក.ប្រជាពលរដ្ឋ

នៅពេលបច្ចុប្បន្ន ក្នុងឃុំព្រែកត្នោតនេះមានចំនួន៤ ភូមិគឺភូមិ ត្រពាំងរពៅ ភូមិ ព្រែកក្រែង ភូមិ ព្រែកត្នោត ភូមិ ចង្ហោន ដែលមានប្រជាពលរដ្ឋសរុបចំនួន១៩១១គ្រួសារ ប៉ុន្តែ សហគមន៍នេសាទព្រែកត្នោត ពាក់ព័ន្ធតែមួយភូមិ គឺភូមិព្រែកត្នោតដែលមានប្រជាពលរដ្ឋចំនួន៣២៧គ្រួសារ ដែលមានមនុស្សសរុបចំនួន១៦៨៣នាក់ ក្នុងស្ត្រីចំនួន៨១៨នាក់ ។ សហគមន៍នេសាទព្រែកត្នោមានសមាជិសសហគមន៍សរុបចំនួន២៤៨ គ្រួសារ ដែលស្មើនឹងចំនួន២៤៨នាក់ ។ ផ្អែកតាមការធ្វើអត្តសញ្ញាណកម្មគ្រួសារក្រីក្រ នៅភូមិព្រែកត្នោតក្នុងឃុំព្រែកត្នោតបានបង្ហាញថា គ្រួសារដែលស្ថិតក្នុងស្ថាន

ភាពក្រីក្រ១ មានចំនួន០៦គ្រួសារ ក្នុងនោះស្រីចំនួន០២គ្រួសារ និងស្ថានភាពក្រីក្រ២ មានចំនួន៣៥គ្រួសារ ក្នុងនោះស្រីចំនួន១០នាក់ ដែលសរុបចំនួន៤១គ្រួសារ ក្នុងនោះស្រីចំនួន១២គ្រួសារ។ ដូច្នេះ ចំនួនសមាជិកសហគមន៍នេសាទមានប្រមាណ១៩ ភាគរយ បើប្រៀបធៀបជាមួយប្រជាពលរដ្ឋគិតជាគ្រួសារនៅក្នុងឃុំនេះ ។

ចំនួនគ្រួសារដែលចូលជាសមាជិកសហគមន៍នេសាទមានចំនួន២៤៨គ្រួសារ ក្នុងនោះគ្រួសារដែលមានស្ត្រីជាមេគ្រួសារមានចំនួន៦៧ គ្រួសារ ប្រជាជនជាជនជាតិខ្មែរគោរពព្រះពុទ្ធសាសនា។ ស្ថានភាពរបស់ប្រជាជនមានដូចជាៈ

- ចំនួនស្ត្រីមេម៉ាយក្នុងសហគមន៍នេសាទមានចំនួន៨៤ នាក់
- ចំនួនបុរសពោះម៉ាយក្នុងសហគមន៍នេសាទមានចំនួន១២ នាក់
- ចំនួនជនពិការក្នុងសហគមន៍នេសាទមានប្រុសចំនួន៣១ នាក់ ក្នុងនោះស្ត្រីមានចំនួន១១ នាក់
- ចំនួនកុមារកំព្រាក្នុងសហគមន៍នេសាទចំនួន២៨ នាក់ ក្នុងនោះកុមារីមានចំនួន១៧ នាក់
- ចំនួនចាស់ជរាក្នុងសហគមន៍នេសាទមានចំនួន៣៧ នាក់ក្នុងនោះស្ត្រីមានចំនួន២៧ នាក់
- ចំនួនអ្នកមានជម្ងឺរាំរ៉ៃក្នុងសហគមន៍នេសាទមានចំនួន២២ នាក់ ក្នុងនោះស្ត្រីមានចំនួន១៦ នាក់
- សាលារៀនបឋមសិក្សាមានចំនួន២ខ្នង ដែលមាន០៦បន្ទប់ មានសិស្សសរុបចំនួន១៩២ នាក់ ក្នុងនោះកុមារីមានចំនួន៩៤ នាក់ ។
- ចំនួនគ្រួសារដែលកើតមេរោគអេដ៍មានចំនួន៥ នាក់ ក្នុងនោះស្ត្រីមានចំនួន០៤ នាក់។
- តាមរបាយការណ៍របស់ក្រុមប្រឹក្សាឃុំព្រែកត្នោត នៅក្នុងសហគមន៍នេសាទនេះបានបង្ហាញថា៨០ នាក់ដែលមិនចេះអក្សរ ក្នុងនោះស្ត្រីចំនួន៦៥ នាក់ ។

**ខ.សេដ្ឋកិច្ចសង្គម**

តាមរបាយការណ៍ និងឯកសារព័ត៌មាន ឃុំឆ្នាំ២០១៧ បានបញ្ជាក់ថា នៅក្នុងសហគមន៍ព្រែកត្នោត មានប្រជាពលរដ្ឋសរុបចំនួន៣២៧ គ្រួសារ ដែលពឹងផ្អែកលើការនេសាទនិងការចិញ្ចឹមត្រី រីឯស្ត្រីគ្រាន់តែជាអ្នកប្រកបមុខរបរបន្ទាប់បន្សំដូចជា កែច្នៃផលត្រី ផ្តល់ចំណីត្រី លក់ដូរជាដើម។ ការគាំទ្រមុខរបរចិញ្ចឹមជីវិតដល់សមាជិកសហគមន៍នេសាទ ជាសកម្មភាពចំបងដែលជួយពង្រីកមុខរបរដល់ប្រជានេសាទនៅក្នុងសហគមន៍ ជាពិសេសបានជួយកាត់បន្ថយសម្ពាធនៃការធ្វើអាជីវកម្មលើធនធានជលផលហួសកំរិត។ កន្លងមក រដ្ឋបាលជលផលនិងអង្គការដៃគូអភិវឌ្ឍន៍បានជួយបណ្តុះបណ្តាលអំពីបច្ចេកទេសការចិញ្ចឹមសត្វ និងការចិញ្ចឹមត្រីលក្ខណៈគ្រួសារ ព្រមទាំងការចិញ្ចឹមជីវិតផ្សេងទៀតដល់សមាជិកសហគមន៍នេសាទ ដើម្បីរួមចំណែកជួយលើកស្ទួយសេដ្ឋកិច្ចគ្រួសារឱ្យមានការរីកចំរើន ។

ពេលបច្ចុប្បន្ន នៅក្នុងសហគមន៍នេសាទព្រែកត្នោត ប្រជាពលរដ្ឋមានស្ថានភាពនៃការចិញ្ចឹមជីវិតនិងមុខរបរសំខាន់ៗរួមមានៈ

- អ្នកដែលមានមុខរបរពឹងផ្អែក លើការនេសាទស្ទើតែទាំងស្រុងមានចំនួន២៨០ គ្រួសារ
- ជាអ្នកធ្វើស្រែ ចិញ្ចឹមសត្វ និងនេសាទចំនួន១២០ គ្រួសារ
- ប្រមូលទិញចំនួន០៦គ្រួសារ
- ចិញ្ចឹមត្រីតក់កែ ត្រីឆ្តោង ក្នុងបែមានចំនួន ០៣ គ្រួសារ ( ៣ម x ៣ម ស្មើ៨០០ក្បាល ) និងក្នុងបែមានចំនួនអ្នកកែច្នៃផលត្រីនិងនេសាទមានសរុបចំនួន ០៦ គ្រួសារ ក្នុងនោះអ្នកកែច្នៃបង្កាក្រៀមមានចំនួន ៤ គ្រួសារ
- អ្នកលក់ដូរចំនួន២០ គ្រួសារ
- ជាងធ្វើម៉ាស៊ីនកាណូត ០៤ គ្រួសារ។

៣.កន្លែងនេសាទ និងធនធានជលផលដែលមាននៅក្នុងកន្លែងនេសាទ

ក.ទីតាំង

សហគមន៍នេសាទព្រែកត្នោត មានទីតាំងស្ថិតក្នុងភូមិព្រែកត្នោតដែលជាដែននេសាទសាធារណៈរបស់រដ្ឋជាដែននេសាទសមុទ្រដែលស្ថិតក្នុងខេត្តកំពត។ កន្លែងនេសាទសហគមន៍នេះមានទំហំ ១១៦៨ ហិកតា ហើយមានកន្លែងអភិរក្សពូជត្រីនិងស្មៅសមុទ្រសំខាន់ៗ។ សហគមន៍នេសាទព្រែកត្នោត ត្រូវបានកំណត់និយាមកាដូចមានចែងនៅក្នុងកិច្ចព្រមព្រៀង និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ប្រកាសទទួលស្គាល់នៅថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១១។

ដូចនេះ សហគមន៍នេសាទព្រែកត្នោតមានព្រំប្រទល់ជាប់នឹង៖

- ខាងជើងទល់នឹង បង្គោលព្រៃលិចទឹក
- ខាងត្បូងទល់នឹងចំងាយពីមាត់ព្រៃកោងកាងចេញក្រៅ ០៣ គីឡូម៉ែត្រ
- ខាងកើតទល់នឹង ឃ្លោងព្រែកស្នាច់ ( សហគមន៍នេសាទចង្ហោន )
- ខាងលិចទល់នឹង ឃ្លោងព្រែកត្នោត ( សហគមន៍នេសាទត្រពាំងរពៅ)។

ខ.ដែននេសាទ

កន្លែងនេសាទសហគមន៍នេសាទព្រែកត្នោត មានវិសាលភាពនៅលើដែននេសាទសមុទ្រដែមានមាទំហំ ១១៦៨ ហិកតា និងកន្លែងអភិរក្សពូជត្រីមួយចំនួនដូចជា៖

ខ.១ ព្រែក អូរ និងអន្លង់

| ល.រ | ឈ្មោះស្ទឹង | ទំហំ/ប្រវែង | រដូវនេសាទ |
|---|---|---|---|
| ១ | ព្រែកស្នាច់ | ០១ គីឡូម៉ែត្រ | ពេញមួយឆ្នាំ |
| ២ | ព្រែកត្នោត | ០៣ គីឡូម៉ែត្រx ៣៥ | ពេញមួយឆ្នាំ |
| ៣ | អូរតាដោក | ០១ គីឡូម៉ែត្រ | ខែមិថុនាដល់ខែធ្នូ |
| ៤ | អូរ អន្លង់ត្រី | ១៥០០ ម | |
| ៥ | ព្រៃកោងកាង | ២០ ហិកតា | |
| ៦ | ទំនាបលិចទឹក | ២០ ហិកតា | |

គ.តំបន់ដែលមានលទ្ធភាពអាចបង្កើតកន្លែងអភិរក្ស

តំបន់ដែលមានលទ្ធភាពអាចបង្កើតកន្លែងអភិរក្សចំនួន០២កន្លែងគឺ នៅចំណុចថ្មតាដោកនិងថ្មដូនណូ(មានផ្កាថ្ម ៥ហិកតា)។ ចំពោះ ថ្មតាដោកសំបូរធនធានជលផលដែលមានទំហំ៧៥០ ហិកតា ក្នុងនោះមានព្រៃកោងកាងទំហំ ២០ ហិកតា និងទំហំ៣៧៥ ហិកតា ជាស្មៅសមុទ្រដែលជាជម្រកវារីសត្វដោយមានទឹកជ្រៅនៅពេលទឹកជរ។ ដោយឡែកមានព្រៃកោងកាងជាជម្រករបស់ពពួកមច្ឆានិងវារីសត្វផ្សេងៗ ដូចជា បង្គា ក្តាម មឹក ងាវ ។ល។

ឃ.ធនធានជលផល

១.ប្រភេទត្រី

នៅក្នុងប្រទេសកម្ពុជា ធនធានជលផលបានដើរតួនាទីយ៉ាងសំខាន់ក្នុងសន្តិសុខស្បៀង ដោយឡែកត្រីអាចផ្តល់ជាអាហារដល់ការចិញ្ចឹមជីវិតរបស់ប្រជាពលរដ្ឋប្រចាំថ្ងៃ។ ផ្អែកតាមការអង្កេតរបស់ក្រុមការងារនិងសមាជិកសហគមន៍ធនធានជលផលក្នុងសហគមន៍នេសាទព្រែកត្នោតមានដូចជា៖

ឃ.១.ប្រភេទត្រីសមុទ្រៈ

ក្នុងសហគមន៍នេសាទព្រែកត្នោតមានប្រភេទត្រីដូចជា៖ ត្រីឆ្កង់ ត្រីក្បក ត្រីប្រកុង ត្រីអាំងកឹយ ត្រីចង្កោមបី ត្រីដំឡូង ត្រីប្លាធូ ត្រីក្ដចិន ត្រីស្លុងក្រហម ត្រីផ្ទោង ត្រីត្រសក់ ត្រីឆ្លាម ត្រីការ៉ាវ ត្រីប្រម៉ា ត្រីកិ ត្រីកន្ទង ត្រីកាម៉ុង ត្រីក្បាលឡាន ត្រីអណ្ដែងប៉ុយ ត្រីកន្ដាំង ត្រីកន្ទុយរឹង ត្រីកាបាស ត្រីបបែល ត្រីឆ្លាត ត្រីក្អុក ត្រីបាលង្គ ត្រីកាឡាំង ត្រីអង្រែ ត្រីគូន ត្រីសេក ត្រីតក់កែ ត្រីផ្ទក់សមុទ្រ ត្រីសេះ។ល។

ឃ.២.ប្រភេទវារីសត្វៈ

ក្នុងសហគមន៍នេសាទ មានប្រភេទវារីសត្វដូជា៖ បង្កង បង្គា ក្ដាមសេះ ក្ដាមថ្ម ក្ដាមជ័រ មឹក គ្រែងឈាម ងាវភក់ ហូល ងាវស បង្កងកណ្ដូប បង្កងប៉ាក អណ្ដើក កន្ទាយ បាលង្កកាស កញ្ចា អន្ទង់ ខ្ញឹង ផ្សោតស ផ្សោតខ្មៅ ផ្សោតប៉ារាពស់។ល។

ឃ.៣.ប្រភេទរុក្ខជាតិព្រៃលិចទឹក និងវារីរុក្ខជាតិៈ

ក្នុងសហគមន៍នេសាទព្រែកត្នោត មានប្រភេទរុក្ខជាតិព្រៃលិចទឹក និងវារីរុក្ខជាតិដូចជា៖ កោងកាង ក្រញឹប អម្ពអម្ពា ក្របាញញី ក្របាញឈ្មោល ប្រសាក់ បើស ឈើជ័រ ដើមក្លាយ ដើមឡេវអាវ។ល។

**៤-ការធ្វើនេសាទ**

តាមការសិក្សា និងប្រមូលទិន្នន័យពីក្រុមប្រឹក្សាឃុំ ភូមិ និងសហគមន៍ព្រែកត្នោតបានបង្ហាញពីចំនួនអ្នកដែលពាក់ព័ន្ធក្នុងការធ្វើនេសាទលើកន្លែងនេសាទសហគមន៍ព្រែកត្នោតមានដូចខាងក្រោម៖

៤.ក.អ្នកនេសាទ

- អ្នកនេសាទជាសមាជិកសហគមន៍នេសាទមានចំនួន២៨០ គ្រួសារមានចំនួន ។
- អ្នកនេសាទមិនមែនជាសមាជិកសហគមន៍នេសាទនៅក្នុងសហគមន៍មានចំនួន៤៧ គ្រួសារ
- តាមការប៉ាន់ស្មានអ្នកនេសាទដែលមកពីខាងក្រៅ ហើយមិនមែនជាសមាជិកដែលជាសហគមន៍មានប្រហែល ៤៨០គ្រួសារ ក្នុង១ឆ្នាំ ។

៤.ខ.ឧបករណ៍នេសាទ

កន្លងមក ប្រជាជននៅក្នុងសហគមន៍នេសាទតែងតែធ្វើនេសាទដោយប្រើប្រាស់ប្រភេទឧបករណ៍នេសាទលក្ខណៈគ្រួសារដូចជា៖ លបក្ដាម មងបង្គា មងត្រីក្បក មងត្រីតាវ៉ាវ មងត្រីការម៉ុង មងត្រីឆ្កង សន្ទូចបបែល លបក្ដាមសេះ ឈិបរុញបង្គាស្មើជើង។ល។ ដូចនេះផងដែរ សមាជិកនិងគណៈកម្មការសហគមន៍បានធ្វើការប៉ាន់ប្រមាណពីតម្រូវការប្រភេទឧបករណ៍នេសាទដែលស្របតាមលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង ផែនទីព្រំប្រទល់កន្លែងនេសាទសហគមន៍ និងផែនការគ្រប់គ្រង ជាពិសេស សមាជិកនិងគណៈកម្មការសហគមន៍នេសាទ ទាមទារសមត្ថកិច្ចជំនាញជលផលធ្វើការផ្សព្វផ្សាយច្រើនជងដល់ប្រជាពលរដ្ឋក្នុសហគមន៍ និងអ្នកនសាទខាងក្រៅលើប្រភេទឧបករណ៍នេសាទដែលហាមឃាត់ ។ ឧបករណ៍នេសាទ និងទូកការណូតរបស់សមាជិកសហគមន៍នេសាទដែលប្រើប្រាស់ក្នុងសហគមន៍នេះដូចជា៖

៤.ខ.ឧបករណ៍នេសាទ

ឧបករណ៍នេសាទ និងទូកកាណូតរបស់សមាជិកសហគមន៍នេសាទដែលប្រើប្រាស់ក្នុងសហគមន៍ព្រែកត្នោតមានដូចជា៖

| ល.រ | ឧបករណ៍នេសាទ | ឯកតា | ប្រវែង/ទំហំ | រដូវនេសាទ |
|---|---|---|---|---|
| ១ | លបក្តាម | លប | ៥០០លប | ពីខែ ១២ ដល់ ខែ ០១ |
| ២ | មងបង្គា | ម៉ែត្រ | ១៥០ម | ពីខែ ១២ ដល់ ខែ ០១ |
| ៣ | មងក្តាម | ម៉ែត្រ | ១៧៥ម | ពីខែ ១១ ដល់ ខែ ០១ |
| ៤ | មងត្រីក្បក | ម៉ែត្រ | ៩០ម | ពេញមួយឆ្នាំ |
| ៥ | មងត្រីតាភរ | ម៉ែត្រ | ៣៥០ | ពេញមួយឆ្នាំ |
| ៦ | មងត្រីផ្ទោង | ម៉ែត្រ | ១៥០ | ពេញមួយឆ្នាំ |
| ៧ | មងត្រីឆ្កុង | ម៉ែត្រ | ៣៥០ | ខែ ១០ ដល់ ខែ ០៤ |
| ៨ | សន្ទូចត្រីអន្ទែងប៉ុយ | ផ្លែ | ១៥០ | ខែ ០៤ ដល់ ខែ ០៧ |
| ៩ | ឈិបរុញបង្គាស្មើជើង | គ្រឿង | ៣ម ទៅ៥ម | ខែ ០១ ដល់ ខែ ១២ |
| ១០ | លបក្តាមសេះ | លប | ២៥០ | ពេញមួយឆ្នាំ |
| ១១ | មងត្រីកន្តាំង | ម៉ែត្រ | ១៥០ | ខែ ០៤ ដល់ ខែ ០៧ |
| ១២ | លបត្រី | លប | ៥០០លប | ពេញមួយឆ្នាំ |
| | | | | |

| ប្រភេទទូក កាណូត | ចំនួន(គ្រឿង) | ចំណុះ(គក) | កំលាំងសេះ |
|---|---|---|---|
| | | | |
| កាណូតម៉ាស៊ីន HONDA | ៥៩ | ១០០០ | ៥ ដល់ ១៣ |
| ទូកចែវ | ២២ | ៥០ | |
| | | | |

**ឧបករណ៍នេសាទ និងទូក កាណូតរបស់អ្នកខាងក្នុងសហគមន៍នេសាទតែមិនមែនជាសមាជិក**

| ល.រ | ឧបករណ៍នេសាទ | ឯកតា | ប្រវែង/ទំហំ | រដូវនេសាទ |
|---|---|---|---|---|
| ១ | លបក្តាម | លប | ៥០០លប | ពីខែ ១២ ដល់ ខែ ០១ |
| ២ | មងបង្គា | ម៉ែត្រ | ១៥០ម | ពីខែ ១២ ដល់ ខែ ០១ |
| ៣ | មងក្តាម | ម៉ែត្រ | ១៧៥ម | ពីខែ ១១ ដល់ ខែ ០១ |
| ៤ | មងត្រីក្បក | ម៉ែត្រ | ៩០ម | ពេញមួយឆ្នាំ |
| ៥ | មងត្រីផ្ទោង | ម៉ែត្រ | ១៥០ | ពេញមួយឆ្នាំ |
| ៦ | មងត្រីការម៉ុង | ម៉ែត្រ | ២៥០ | ពីខែ ០៤ ដល់ ខែ ០៦ |
| ៧ | មងត្រីកន្តាំង | ម៉ែត្រ | ១៥០ | ខែ ០៤ ដល់ ខែ ០៧ |

| ប្រភេទទូក កាណូត | ចំនួន(គ្រឿង) | ចំណុះ(គក) | កំលាំងសេះ |
|---|---|---|---|
| កាណូតម៉ាស៊ីន CHHANG VA | ២ | ១០០០ | ១០ |
| កាណូតម៉ាស៊ីន YANMAR | ៤០ | ១០០០ | ៦ ដល់ ១៣ |

ឧបករណ៍នេសាទ និងទូក កាណូតរបស់អ្នកមិនមែនជាសមាជិកដែលមកពីក្រៅសហគមន៍នេសាទ

| ល.រ | ឧបករណ៍នេសាទ | ឯកតា | ប្រវែង/ទំហំ/គ្រួសារ | រដូវនេសាទ |
|---|---|---|---|---|
| ១ | លបក្តាម | លប | ៥០០លប | ពីខែ ១២ ដល់ ខែ ០១ |
| ២ | មងបង្គា | ម៉ែត្រ | ១៥០ម | ពីខែ ១២ ដល់ ខែ ០១ |
| ៣ | មងក្តាម | ម៉ែត្រ | ១៧៥ម | ពីខែ ១១ ដល់ ខែ ០១ |
| ៤ | មងត្រីក្បក | ម៉ែត្រ | ៩០ម | ពេញមួយឆ្នាំ |
| ៥ | មងត្រីផ្ទោង | ម៉ែត្រ | ១៥០ | ពេញមួយឆ្នាំ |
| ៦ | មងត្រីការម៉ុង | ម៉ែត្រ | ២៥០ | ពីខែ ០៤ ដល់ ខែ ០៦ |

| ប្រភេទទូកកាណូត | ចំនួន(គ្រឿង) | ចំណុះ(គក) | កំលាំងសេះ |
|---|---|---|---|
| កាណូតម៉ាស៊ីន HONDA | ៥០ | ១០០០ | ៦ ដល់ ១៣ |
| កាណូតម៉ាស៊ីន CHHANG VA | ៥ | ១០០០ | ១០ |
| ទូកចែវ | ១០ | ៥០ | |

ការប្រើប្រាស់ឧបករណ៍នេសាទរបស់សមាជិកសហគមន៍នេសាទ ត្រូវស្របតាមប្រកាសស្តីពីការកំណត់ប្រភេទឧបករណ៍នេសាទដែលអនុញ្ញាតិឱ្យធ្វើនេសាទក្នុងដែនសមុទ្រនៃព្រះរាជាណាចក្រកម្ពុជា របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទលេខ ៣១៩ ប្រក.កសក ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៥។

**គ.ការប៉ាន់ប្រមាណផលនេសាទចាប់បានប្រចាំឆ្នាំ**

| ប្រភេទផលនេសាទ | បរិមាណផលនេសាទចាប់បានគិតជាមធ្យមប្រចាំគ្រួសារ (គិតជាគក្រ) | | |
|---|---|---|---|
| | រដូវប្រាំង | រដូវវស្សា | សរុបប្រចាំឆ្នាំ |
| ត្រីគ្រប់ប្រភេទ | ៣៤៣ | ៤៥៦ | ៧៩៩ |
| បង្គា | ២២៨ | ៣០៧ | ៥៣៥ |
| ក្តាម | ២២១ | ២៨៧ | ៥០៨ |
| មឹក ខ្យង និងក្រែមងឈាម | ១៤៧ | ១៧៦ | ៣២៣ |
| **សរុប** | **៩៣៩** | **១២២៦** | **២១៦៥** |

## ៩.ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

### ក.ទស្សនៈវិស័យ

សហគមន៍នេសាទព្រៃកន្ទោតមានទស្សនៈវិស័យរួមចំណែកគ្រប់គ្រង និងប្រើប្រាស់ធនធានជលផលប្រកបដោយសមធម៌និងចីរភាព ដើម្បីរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ។

### ខ.គោលបំណង

- ចូលរួមគ្រប់គ្រងដែននេសាទសមុទ្រជាកន្លែងនេសាទគ្រួសារ ដែលរក្សាទុកសម្រាប់ប្រជាពលរដ្ឋធ្វើនេសាទជាប្រពៃណីឬសហគមន៍ធ្វើនេសាទទំនាបលិចទឹក ក្នុងរដូវទឹកជោរ និងព្រៃកោងកាងនិងកន្លែងអន្លង់អភិរក្ស។
- ចូលរួមគ្រប់គ្រងធនធានជលផលប្រកបដោយនិរន្តរភាព និងធានាការបែងចែកផលប្រយោជន៍ធនធានជលផលជូនប្រជាពលរដ្ឋខ្មែរប្រកបដោយសមធម៌។
- ដើម្បីធ្វើឱ្យប្រសើរឡើងនូវជីវភាពសមាជិកសហគមន៍នេសាទ តាមរយៈការអភិវឌ្ឍន៍ចំរុះ
- ដើម្បីឲ្យប្រជាពលរដ្ឋបានយល់ច្បាស់ហើយនឹងឈានទៅចាត់ទុកថាខ្លួនជាម្ចាស់ផ្ទាល់លើធនធានធម្មជាតិ។

### គ.ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

#### គ.១.ផែនការប្រើប្រាស់ឧបករណ៍នេសាទៈ

#### គោលបំណង

ផែនការប្រើប្រាស់ឧបករណ៍នេសាទនៅក្នុងកន្លែងនេសាទសហគមន៍ព្រៃកន្ទោត រៀបចំឡើងដោយបានគិតគូរអំពីប្រភេទដែននេសាទ ប្រភេទទំហំ ប្រវែងចំនួនឧបករណ៍នេសាទចំនួនអ្នកនេសាទនិងរដូវនេសាទ និងការប៉ាន់ប្រមាណផលស្តុកដែលមាននៅក្នុងដែននេសាទ ដោយធ្វើយ៉ាងណាមិនឱ្យការធ្វើនេសាទលើសពីតម្រូវការធនធានជលផលដែលមានក្នុងកន្លែងសហគមន៍នេសាទ។

**ផែនការប្រើប្រាស់ឧបករណ៍នេសាទនៅក្នុងកន្លែងនេសាទត្រូវបានរៀបចំឡើងដូចខាងក្រោមៈ**

| ល.រ | ឧបករណ៍នេសាទ | ឯកតា | ប្រវែង/ទំហំ | រដូវនេសាទ |
|---|---|---|---|---|
| ១ | លបក្តាម | លប | ៥០០ | ពីខែ ១២ ដល់ ខែ ០១ |
| ២ | មងបង្គា | ម៉ែត្រ | ១៥០ | ពីខែ ១២ ដល់ ខែ ០១ |
| ៣ | មងក្តាម | ម៉ែត្រ | ១៧៥ | ពីខែ ១១ ដល់ ខែ ០១ |
| ៤ | មងត្រីក្បក | ម៉ែត្រ | ៩០ | ពេញមួយឆ្នាំ |
| ៥ | មងត្រីតាវ | ម៉ែត្រ | ៣៥០ | ពេញមួយឆ្នាំ |
| ៦ | មងត្រីផ្ទោង | ម៉ែត្រ | ១៥០ | ពេញមួយឆ្នាំ |
| ៧ | មងត្រីការម៉ុង | ម៉ែត្រ | ២៥០ | ពីខែ ០៤ ដល់ ខែ ០៦ |
| ៨ | មងត្រីគូន | ម៉ែត្រ | ៣០ | ពីខែ ០៩ ដល់ ខែ ១២ |
| ៩ | មងត្រីឆ្កង | ម៉ែត្រ | ៣៥០ | ខែ ១០ ដល់ ខែ ០៤ |
| ១០ | សន្ទូចបបែល | ផ្លែ | ៥០០ | ខែ ០៤ ដល់ ខែ ០៧ |
| ១១ | សន្ទូចត្រីក្អុក | ផ្លែ | ១៥០ | ខែ ០៤ ដល់ ខែ ០៧ |

| | | | | |
|---|---|---|---|---|
| ១២ | សន្ទូចត្រីអន្ទែងប៉ុយ | ផ្លែ | ១៥០ | ខែ ០៤ ដល់ ខែ ០៧ |
| ១៣ | ឈិបរុញបង្គាស្មើជើង | គ្រឿង | ៣ម ទៅ៥ម | ខែ ០១ ដល់ ខែ ១២ |
| ១៤ | លបក្តាមសេះ | លប | ២៥០ | ពេញមួយឆ្នាំ |
| ១៥ | មងត្រីកន្ធាំង | ម៉ែត្រ | ១៥០ | ខែ ០៤ ដល់ ខែ ០៧ |

| ល.រ | ឈ្មោះ/ទីតាំង កន្លែងនេសាទ | ពេលវេលា ធ្វើនេសាទ | ឧបករណ៍នេសាទអនុញ្ញាតឲ្យប្រើ | | |
|---|---|---|---|---|---|
| | | | ប្រភេទ | ទំហំ/ប្រវែង | ផ្សេង |
| ១ | ព្រែកថ្មតាដោក | ពេញមួយឆ្នាំ | ការប្រើប្រាស់ឧបករណ៍នេសាទរបស់សមាជិកសហគមន៍នេសាទត្រូវស្រប គឺស្របតាមប្រកាសស្តីពីការកំណត់ប្រភេទឧបករណ៍នេសាទដែលអនុញ្ញាតិឱ្យធ្វើនេសាទក្នុងដែនសមុទ្រនៃព្រះរាជាណាចក្រកម្ពុជា របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ លេខ ៣១៩ ប្រក.កសក ចុះថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០១៥។ | | |
| ២ | ព្រែកថ្មដូនណូ | ពេញមួយឆ្នាំ | | | |

**គ.២.ផែនការកែលំអដែននេសាទ**

ផែនការកែលំអដែននេសាទ គឺជាការងារមួយដែលត្រូវទាមទារមានការគាំទ្របច្ចេកទេសនិងថវិកា និងប្រើប្រាស់ពេលវេលាធ្វើការសិក្សាមួយច្បាស់លាស់ពីព្រោះថា ការកែលំអដែននេសាទសហគមន៍នេះវាពាក់ព័ន្ធជាមួយត្រីមេពូជនិងវារីសត្វគ្រប់ប្រភេទនៅក្នុងដែននេសាទនោះ។ ដូចនេះផងដែរ ក្នុងកិច្ចប្រជុំរវាងគណៈកម្មការនិងសមាជិកសហគមន៍នេសាទ អាជ្ញាធរមូលដ្ឋាន និងក្រុមសម្របសម្រួលរដ្ឋបាលជលផលថ្នាក់កណ្តាលបានពិនិត្យឃើញថា ដែននេសាទនៅក្នុងសហគមន៍នេសាទនេះមានសភាពប្រែប្រួលខ្លះដែលបណ្តាលមកពីកត្តាមនុស្សនិងធម្មជាតិ ។

ផែនការកែលំអដែននេសាទ ក្នុងគោលបំណង៖

- បង្កើនផលត្រី និងវារីសត្វគ្រប់ប្រភេទ និងជួយថែរក្សាលំនឹងបរិស្ថានធម្មជាតិ ។
- ធ្វើឱ្យសំបូរព្រៃលិចទឹកឱ្យនៅក្នុងដែននេសាទសហគមន៍។

ផែនការកែលំអដែននេសាទ នឹងត្រូវរៀបចំដូចមានក្នុងតារាងខាងក្រោម៖

| ឈ្មោះដែន នេសាទ | ទំហំ | ទំហំដែល ត្រូវកែលំអ | សកម្មភាព | ថ្ងៃខែឆ្នាំ ចាប់ផ្តើម | ថ្ងៃខែឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|
| ខោសតាពូ | ១៥ ហត | ២,៥ ហត | ដាំកូនកោងកាង | ខែមិថុនាឆ្នាំ២០២០ | ខែមិថុនាឆ្នាំ ២០២៣ |

គ.៣.ផែនការរៀបចំកន្លែងអភិរក្ស

សហគមន៍នេសាទព្រែកត្នោត បានសម្រេចក្នុងការបង្កើតកន្លែងអភិរក្សចំនួន០២កន្លែងគឺ ព្រែកក្ដាម និងថ្មបីដុំ ដែលជាកន្លែងមានសក្ដានុពលសម្រាប់អភិរក្សត្រីមេពូជ ក្ដាម មឹក។ ដូចនេះផងដែរ កន្លែងអភិរក្សបានធ្វើការគ្រប់គ្រង បន្ទាប់ពីសហគមន៍នេសាទនេះ ត្រូវបានប្រកាសទទួលស្គាល់ដោយក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ ហើយ កន្លែងអភិរក្សត្រីមេពូជទាំងពីរ នេះបង្កើតឡើងក្នុងគោលបំណង៖

- បង្កើនពូជត្រី និងសត្វគ្រប់ប្រភេទ
- ជាជម្រកនិងប្រភពចំណីរបស់ត្រីនិងសត្វ
- ផ្ដល់ចំណេះដឹងដល់ប្រជាពលរដ្ឋ ឱ្យចេះស្រឡាញ់ថែរក្សា ការពារធនធានធម្មជាតិ និង
- ពិសេស ធនធានជលផល បរិស្ថាន និងចូលរួមលុបបំបាត់ការនេសាទខុសច្បាប់។

តាមការចុះអង្កេតនិងពិនិត្យរបស់ក្រុមការងារ និងពិភាក្សាលើលក្ខណៈវិនិច្ឆ័យជាមួយគណៈកម្មការ និង សមាជិកសហគមន៍នសាទព្រែកត្នោតបានបញ្ជាក់ថា៖ កន្លែងអភិរក្សព្រែកក្ដាមនិងថ្មបីដុំ គឺជាកន្លែងសំខាន់បំផុតសម្រាប់ ធ្វើការអភិរក្សដែលសមាជិកសហគមន៍នេះ មានសុឆន្ទៈចង់ចូលរួមក្នុងការគ្រប់គ្រងធនធានជលផលដើម្បីធានានូវប្រសិទ្ធ នៃការគ្រប់គ្រងធនធានជលផល និងជាប្រយោជន៍សម្រាប់តម្រូវការផលត្រីរបស់ប្រជាពលរដ្ឋក្នុងសហគមន៍ ។

កន្លែងអភិរក្សត្រីមេពូជ ជាកត្តាចាំបាច់ដែលត្រូវរៀបចំកំណត់ព្រំប្រទល់ បោះបង្គលស៊ីម៉ងព្រំប្រទល់ ធ្វើប៉ាណូ ផ្សព្វផ្សាយ ក្ដាខៀនព័ត៌មាន បិទផ្សាយបទបញ្ញត្តិផ្សេងសម្រាប់កន្លែងអភិរក្ស សាងសង់រោងយាមសម្រាប់ក្រុមល្បាត បំពេញការងារ មធ្យោបាយនិងសម្ភារៈផ្សេងទៀត។

ផែនការកំណត់ និងរៀបចំកន្លែងអភិរក្សនឹងត្រូវរៀបចំដូចមានក្នុងតារាងខាងក្រោម៖

| ឈ្មោះ/ទីតាំង | ទំហំ (ហត) | ប្រភេទនៃការអភិរក្ស | សកម្មភាព | ថ្ងៃខែឆ្នាំ ចាប់ផ្ដើម | ថ្ងៃខែឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|
| ព្រែកក្ដាម | ០៣ | • ប្រភេទត្រីសំខាន់<br>• ប្រភេទសត្វស្លាប<br>• ប្រភេទពពួកល្មូន<br>• ព្រៃលិចទឹក | • ផ្សព្វផ្សាយដល់ប្រជាពលរដ្ឋ<br>• ចុះល្បាតជាប្រចាំ<br>• បោះបង្គោលស៊ីម៉ង់ចំនួន ១០ដើម<br>• ប្រអប់សិប្បនិមមិត្ត ១០ | ២០២០ | ២០២៣ |
| ថ្មបីដុំ | ៣០០ | • ប្រភេទត្រីសំខាន់<br>• ប្រភេទសត្វស្លាប<br>• ប្រភេទពពួកល្មូន | • សិក្សាពីកន្លែងអភិរក្ស<br>• បោះបង្គោលស៊ីម៉ង់ចំនួន ១០ ដើម<br>• ផ្សព្វផ្សាយ<br>• ប្រអប់សិប្បនិមមិត្ត ១០<br>• ចុះល្បាតជាប្រចាំ | ២០២០ | ២០២៣ |

### គ.៤.ផែនការគ្រប់គ្រងព្រៃកោងកាង

នាទីព្រៃកោងកាងមានគ្របដណ្តប់លើដែននេសាទសហគមន៍ព្រែកត្នោតដែលបានផ្តល់នូវសក្តានុពលនិងសារៈប្រយោជន៍ជាច្រើនដល់ប្រភេទត្រី សត្វល្មូន ប្រភេទសត្វ និងវារីសត្វផ្សេងទៀតសម្រាប់ជាជម្រករស់នៅបង្កកំណើតជាកូននិងជាចំណីផងដែរ។ ដូចនេះផែនការគ្រប់គ្រងព្រៃកោងកាងក្នុងគោបំណង៖

- ថែរក្សា ការពារព្រៃកោងកាងឱ្យនៅគង់វង្សយូរអង្វែងក្មេងជំនាន់ក្រោយ។
- ទុកជាជម្រកត្រី និងវារីសត្វគ្រប់ប្រភេទ និងជួយថែរក្សាលំនឹងបរិស្ថានធម្មជាតិ ទប់ស្កាត់ការហូរច្រោះទឹករលក និងជារបាំងខ្យល់។
- បង្កើនទិន្នផលត្រី និងពពួកសត្វគ្រប់ប្រភេទឱ្យសំបូរឡើងដើម្បីលើកកម្ពស់ជីវភាពរស់នៅរបស់សហគមន៍។

គណៈកម្មការនិងសមាជិកសហគមន៍នេសាទ បានគ្រប់គ្រងព្រៃកោងកាង និងកន្លែងប្រើប្រាស់ ដោយផ្អែកតាមផែនទីសហគមន៍នេសាទ។ ព្រៃកោងកាង ត្រូវអប់រំណែនាំដល់ប្រជាពលរដ្ឋឱ្យយល់ដឹងពីសារៈសំខាន់របស់វា។

ខាងក្រោមនេះ ជាផែនការគ្រប់គ្រងនាទីព្រៃកោងកាងក្នុងសហគមន៍ព្រែកត្នោតមានដូចជា៖

| ឈ្មោះ/ទីតាំង | ទំហំ ហត | ប្រភេទកូនឈើដែលត្រូវការពារ | សកម្មភាព | ថ្ងៃខែឆ្នាំ ចាប់ផ្តើម | ថ្ងៃខែឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|
| ខោសទំពូ | ២,៥ | ដើមកោកាង | • ផ្សព្វផ្សាយពីផលប្រយោជន៍នៃការគ្រប់គ្រងព្រៃលិចទឹក | ៥/៥/២១ | ៦/៥/២១ |
| | | | • រៀបចំកូនឈើ | ១៥/៦/២១ | ១៧/៦/២១ |
| | | | • ពីធីដាំកូនឈើ និងដាក់ស្លាកសញ្ញា | ២០/៦/២១ | ២២/៦/២១ |
| | | | • ថែរក្សា និងការពារ | ២០/៦/២១ | ១០/១២/២១ |
| អូរតាដោក | ២០ | ថែរក្សានិងការពារព្រៃកោហកាង | • ផ្សព្វផ្សាយការគ្រប់គ្រងព្រៃលិចទឹក | ៣០/៦/២០ | ៣០/៦/២៣ |
| | | | • ដាក់ស្លាកសញ្ញាការពារ | | |
| | | | • ត្រួតពិនិត្យ និងការពារ | ជាប្រចាំ | |

### គ.៥.ផែនការអភិវឌ្ឍន៍វារីវប្បកម្ម

ក្រៅពីនេសាទត្រី ការចិញ្ចឹមត្រីជាមុខរបរមួយបន្ថែមរបស់ប្រពលរដ្ឋនៅក្នុងសហគន៍នេះ។ ជាទូទៅ ប្រជាពលរដ្ឋក្នុងសហគមន៍នេសាទនេះ ច្រើនចិញ្ចឹមត្រីនៅតាមបែមានដូចជា៖ ត្រីស្តុង ត្រីតកកែ ក្តាមសេះនិងគ្រែងឈាម។ ការចិញ្ចឹមត្រីជាទម្លាប់របស់ប្រជាពលរដ្ឋកម្ពុជាជាយូឆ្នាំមកហើយ ដោយអ្នកខ្លះចាប់បានពូជត្រីពីធម្មជាតិ អ្នកខ្លះទៀតចិញ្ចឹមដូចលក្ខណៈប្រស់ ឬចិញ្ចឹមបំប៉នឱ្យមានទំហំសមស្របសម្រាប់តម្រូវការទីផ្សារ។

ការចិញ្ចឹមត្រីជាទិសដៅដ៏សំខាន់របស់វិស័យជលផល ក្នុងការបង្កើនត្រីសាច់សម្រាប់ហូបចុករបស់ប្រជាពលរដ្ឋក្នុងមូលដ្ឋាន និងសម្រាប់នាំចេញទៅទីផ្សារអន្តរជាតិ ដើម្បីរួមចំណែកជួយលើកស្ទួយសេដ្ឋកិច្ចគ្រួសារឱ្យមានការរីកចំរើន។ ថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១៦ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានចេញប្រកាសលេខ ៣២៥ ប្រក ក សកស្តីពី ការគ្រប់គ្រងការចិញ្ចឹមត្រីរស់ ត្រីឆ្តោរ ដែលស្របនឹងតម្រូវការប្រជាពលរដ្ឋនៅមូលដ្ឋាន។ ជាក់ស្តែងសហគមន៍

នេសាទនេះ បានចិញ្ចឹមត្រីតាមស្រះដែលការចិញ្ចឹមត្រីមានដូចជាៈ ត្រីស្គង ធនាគារក្ដាមនិងត្រីតក់កែ ពីព្រោះសហគមន៍នេះស្ថិតនៅតាមឆ្នេរសមុទ្រ។ ការអភិវឌ្ឍន៍វារីវប្បកម្មរបស់សហគមន៍នេសាទនេះក្នុងគោលបំណងៈ

- បង្កើនត្រីសាច់សម្រាប់ហូបចុក របស់ប្រជាពលរដ្ឋក្នុងមូលដ្ឋាន
- បង្កើនប្រាក់ចំណូលដែលជួយស្ដួយសេដ្ឋកិច្ចគ្រួសារ
- កាត់បន្ថយសម្ពាធអាជីវកម្មលើធនធានជលផលហួសកំរិត។

ឆ្លើយតបនឹងទៅនឹងការពង្រីកការអភិវឌ្ឍន៍វារីវប្បកម្ម គណៈកម្មការនិងសមាជិកសហគមន៍នេសាទនេះ បានរៀបចំផែនការអភិវឌ្ឍន៍ការចិញ្ចឹមត្រីដូចខាងក្រោមៈ

| ប្រភេទ វារីវប្បកម្ម | សកម្មភាព | ទំហំ | ប្រភេទកូនត្រីពូជ | បរិមាណកូនត្រីពូជ (ក្បាល) | ខែ/ឆ្នាំ | |
|---|---|---|---|---|---|---|
| | | | | | ចាប់ផ្ដើម | ប្រមូលផល |
| ចិញ្ចឹមត្រីស្គង និងត្រីតក់កែ តាមបច្ចេកទេសជាលក្ខណៈគ្រួសារ ចំនួន ៦ គ្រួសារ | • ជ្រើសរើសគ្រួសារកសិករស្ម័គ្រចិត្ត<br>• បច្ចេកទេសចិញ្ចឹមត្រីជាលក្ខណៈគ្រួសារ<br>• ធ្វើបែចិញ្ចឹម<br>• ផ្ដល់កូនត្រី<br>• តាមដានត្រួតពិនិត្យ | ១បែ= ៤មx ៤ ម | កូនត្រីតក់កែ កូនត្រីស្គង | ៣០០ | ២០២០ | ២០២៣ |
| ចិញ្ចឹមគ្រែងឈាម | • ជ្រើសរើសគ្រួសារកសិករស្ម័គ្រចិត្ត<br>• បច្ចេកទេសចិញ្ចឹមគ្រែងឈាមជាលក្ខណៈគ្រួសារ<br>• ផ្ដល់កូនគ្រែងឈាម<br>• តាមដានត្រួតពិនិត្យ | ផ្ទៃដីទំហំ ២ ហិកតា | កូនគ្រែងឈាម | ១២០០គក | ២០២០ | ២០២៣ |
| ធនាគារក្ដាម **សរុបចំនួន ៣បែ** | • ជ្រើសរើសគ្រួសារកសិករស្ម័គ្រចិត្ត<br>• បច្ចេកទេសចិញ្ចឹម<br>• ជាលក្ខណៈគ្រួសារ<br>• ធ្វើបែចិញ្ចឹម<br>• ការដាក់មេក្ដាម<br>• តាមដានត្រួតពិនិត្យ | ១បែ= ៤មx ៤ ម | មេក្ដាម | ៦០០ក្ដាម/ ១បែ | ២០២០ | ២០២៣ |

គ.៦.ផែនការអភិវឌ្ឍន៍មុខរបរទ្រទ្រង់ជីវភាព

ការគាំទ្រមុខរបរចិញ្ចឹមជីវិតដល់សមាជិកសហគមន៍នេសាទ ជាសកម្មភាពចំបងដែលជួយពង្រីកមុខរបរដល់ប្រជានេសាទនៅក្នុងសហគមន៍ ជាពិសេស បានជួយកាត់បន្ថយសម្ពាធនៃការធ្វើអាជីវកម្មលើធនធានជលផលហួសកំរិត។ កន្លងមករដ្ឋបាលជលផលនិងអង្គការដៃគូអភិវឌ្ឍន៍បានជួយបណ្តុះបណ្តាលអំពីបច្ចេកទេសការចិញ្ចឹមសត្វនិងការចិញ្ចឹមត្រីលក្ខណៈគ្រួសារ ព្រមទាំងការចិញ្ចឹមជីវិតផ្សេងៗទៀតដល់សមាជិកសហគមន៍នេសាទ ដើម្បីរួមចំណែកជួយលើកស្ទួយសេដ្ឋកិច្ចគ្រួសារក្នុងគោលបំណង៖

- ដើម្បីឱ្យប្រជាពលរដ្ឋមានមុខរបរបង្កើនប្រាក់ចំណូល
- ជួយកាត់បន្ថយអត្រាចំណាកស្រុក
- ផ្តល់ចំណេះដឹងជំនាញនិងបច្ចេកទេស (ចិញ្ចឹមសត្វ កសិកម្មសមស្រប)

| ប្រភេទមុខរបរ | សកម្មភាព | ប្រភេទពូជ (ក្បាល) | បរិមាណ | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំប្រមូលផល |
|---|---|---|---|---|---|
| ១០គ្រួសារចិញ្ចឹមមាន់ តាមបច្ចេកទេសជាលក្ខណៈគ្រួសារ | • ជ្រើសរើសកសិករស្ម័គ្រចិត្ត<br>• បណ្តុះបណ្តាលចិញ្ចឹមជ្រូក<br>• អនុវត្តន៍ជាក់ស្តែង<br>• ជ្រើសរើសនិងធ្វើទ្រុង<br>• ទិញពូជនិងដាក់ពូជចិញ្ចឹម<br>• តាមដានត្រួតពិនិត្យ | មាន់ | ៦ក្បាល/គ្រួសារ | ២០២០ | ២០២៣ |

គ.៧.ផែនការអភិវឌ្ឍន៍កន្លែងកំសាន្តរបស់សហគមន៍

ពេលបច្ចុប្បន្ន សហគមន៍នេសាទ នឹងគ្រោងផែនការរៀបចំកន្លែងកំសាន្តនៅតាមឆ្នេរសមុទ្រ ដែលអាចជួយកាត់បន្ថយអត្រាចំណាកស្រុករបស់សមាជិកសហគមន៍នេសាទ និងកាត់បន្ថយសម្ពាធអាជីវកម្មលើធនធានជលផលហួសកំរិតដើម្បីឱ្យសហគមន៍មានដើមទុនសម្រាប់អនុវត្តការងារដោយខ្លួនឯងសម្រាប់ការចូលរួមចំណែកក្នុងការគ្រប់គ្រង និងប្រើប្រាស់ធនធានជលផលប្រកបដោយនិរន្តភាព។ ផែនការអភិវឌ្ឍន៍កន្លែងកំសាន្តរបស់សហគមន៍ក្នុងគោលបំណង៖

- បង្កើនប្រាក់ចំណូលដែលជួយស្ទួយសេដ្ឋកិច្ចគ្រួសារ
- ជួយកាត់បន្ថយអត្រាចំណាកស្រុករបស់សមាជិកសហគមន៍នេសាទ
- កាត់បន្ថយសម្ពាធការធ្វើអាជីវកម្មលើធនធានជលផលហួសកំរិត។
- កាត់បន្ថយអត្រាការប្រាក់ខ្ពស់ និងខ្ចីប្រាក់ពីឈ្មួញ និង
- ដើម្បីឱ្យសហគមន៍មានដើមទុនសម្រាប់អនុវត្តការងារដោយខ្លួនឯង។

| ប្រភេទមុខរបរ | សកម្មភាព | ថ្ងៃខែឆ្នាំ ចាប់ផ្ដើម | ថ្ងៃខែឆ្នាំ បញ្ចប់ |
|---|---|---|---|
| ការបង្កើតកន្លែងកំសាន្តរបស់សហគមន៍នេសាទព្រែកត្នោត | • ផ្សព្វផ្សាយទស្សនៈដល់សមាជិកសហគមន៍<br>• ការរៀបចំក្រុមសម្រាប់អនុវត្ត<br>• បង្កើតគោលការណ៍ និងបទបញ្ជាផ្ទៃក្នុង<br>• បណ្តុះបណ្តាលពីការរៀបចំឯកសារនិងថវិកា<br>• ត្រួតពិនិត្យតាមដាន | ២០២០ | ២០២១ |

**គ.៨.ផែនការពង្រឹងសមត្ថភាពគណៈកម្មការសហគមន៍នេសាទ**

ជាទូទៅ បេក្ខជនដែលឈរឈ្មោះជាគណៈកម្មការសហគមន៍នេសាទគួរត្រូវបានបញ្ជាក់ពីគុណភាព និងចំណេះដឹងដូចជាៈ ចេះអាន សរសេរ អាកប្បកិរិយាសមរម្យ ដោយឯកភាពពីសមាជិកសហគមន៍ ហើយការរៀបចំបោះឆ្នោតជ្រើសរើសជាគណៈកម្មការបានប្រើនីតិវិធីដែលស្របតាមគោលការណ៍ណែនាំសហគមន៍នេសាទ ដែលបានអនុម័តដោយក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ។ ជាក់ស្តែង គណៈកម្មការសហគមន៍នេសាទនេះ ត្រូវបានជ្រើសរើសតាមរយៈការបោះឆ្នោតដោយត្រឹមត្រូវ និងយុត្តិធម៌ដែលមានសំឡេងគាំទ្រច្រើនជាងគេ ហើយជាញឹកញាប់សមាសភាពគណៈកម្មការសហគមន៍នេសាទ មានកំរិតលើការយល់ដឹងពីលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង ជំនាញសម្របសម្រួល ទំនាក់ទំនងជាមួយដៃគូអភិវឌ្ឍន៍ និងការរៀបផែនការគ្រប់គ្រងកន្លែង សហគមន៍នេសាទ។ ដូចនេះ ផែនការបណ្តុះបណ្តាលដល់សមាសភាពគណៈកម្មការសហគមន៍នេសាទ នឹងត្រូវបានរៀបចំក្នុងគោលបំណងៈ

- យល់ពីតួនាទីនិងភារកិច្ចរបស់ពួកគាត់ និង
- បង្កើនសាមគ្គីភាពនិងការទំនាក់ទំនងល្អជាមួយសហគមន៍ និងអ្នកពាក់ព័ន្ធ
- គណៈកម្មការសហគមន៍នេសាទនឹងអាចអនុវត្តសកម្មភាពក្នុងការងារ។

| លរ | សកម្មភាព | ចំនួន | ថ្ងៃខែឆ្នាំ ចាប់ផ្ដើម | ថ្ងៃខែឆ្នាំ បញ្ចប់ |
|---|---|---|---|---|
| ១ | បណ្តុះបណ្តាលរបៀបធ្វើកំណត់ហេតុ សរសេរលិខិត រដ្ឋបាល របាយការណ៍ និងរៀបចំទុកឯកសារ | ១លើក | ២០២០ | ២០២០ |
| ២ | បណ្តុះបណ្តាលការគ្រប់គ្រងថវិកា | ១លើក | ២០២១ | ២០២១ |
| ៣ | បណ្តុះបណ្តាលការដោះស្រាយទំនាស់ | ១លើក | ២០២១ | ២០២១ |
| ៤ | បណ្តុះបណ្តាលជំនាញក្នុងការសម្របសម្រួល | ១លើក | ២០២២ | ២០២២ |
| ៥ | បណ្តុះបណ្តាលការរៀបចំផែនការ | ១លើក | ២០២៣ | ២០២៣ |

### គ.៩.ផែនការផ្សព្វផ្សាយពីច្បាប់ជលផល និងលិខិតបទដ្ឋានពាក់ព័ន្ធ

ពេលបច្ចុប្បន្ន ធនធានជលផលក្នុងសហគមន៍កំពុងទទួលរងនូវការគំរាមកំហែងពីអ្នកខាងក្នុងនិងខាងក្រៅដោយការប្រើប្រាស់ឧបករណ៍នេសាទល្មើសច្បាប់។ ដូចនេះ ដើម្បីធានាការប្រើប្រាស់ធនធានជលផលពេលអនាគតនិងបានយូរអង្វែងនោះតម្រូវធ្វើការផ្សព្វផ្សាយអំពីច្បាប់ស្តីពី ជលផលនិងលិខិតបទដ្ឋានពាក់ព័ន្ធឱ្យបានទូលំទូលាយដល់ប្រជាពលរដ្ឋនៅមូលដ្ឋាន ដើម្បីឱ្យមានការយល់ដឹងគ្រប់គ្រាន់ និងចូលរួមចំណែកក្នុងការគ្រប់គ្រង និងប្រើប្រាស់ធនធានជលផលប្រកបដោយចីរភាព ។ ការផ្សព្វផ្សាយអំពីច្បាប់ស្តីពីជលផលនិងលិខិតបទដ្ឋានពាក់ព័ន្ធក្នុងគោលបំណង៖

- បង្កើនការយល់ដឹងដល់ប្រជាពលរដ្ឋក្នុងសហគមន៍
- កាត់បន្ថយសកម្មភាពបទល្មើសនេសាទក្នុងសហគមន៍

ផែនការសកម្មភាពមានដូចខាងក្រោម៖

| ឈ្មោះសកម្មភាព | អ្នកទទួលខុសត្រូវ | រយៈពេលអនុវត្ត | | | តម្លៃប៉ាន់ស្មាន (គិតជារៀល) | ប្រភពទុន |
|---|---|---|---|---|---|---|
| | | ឆ្នាំទី១ | ឆ្នាំទី២ | ឆ្នាំទី៣ | | |
| ផ្សព្វផ្សាយពីច្បាប់ជលផល និងលិខិតបទដ្ឋានពាក់ព័ន្ធ | ខណ្ឌរដ្ឋបាលជលផល | ៤ | ៤ | ៤ | ៤.០០០.០០០ | ថវិកាឃុំ កម្មវិធី |
| ផ្សព្វផ្សាយលក្ខន្តិកៈនិងបទបញ្ជាផ្ទៃ | គណៈកម្មការ | ៤ | ៤ | ៤ | ២.២៥០.០០០ | ថវិកាឃុំ ដៃគូអភិវឌ្ឍ |

### គ.១០.ផែនការសង់ស្នាក់ការសហគមន៍នេសាទ

ពេលបច្ចុប្បន្ន សហគមន៍នេសាទនេះពុំទាន់មានស្នាក់ការសម្រាប់គណៈកម្មការសហគមន៍នេសាទធ្វើការនៅឡើយទេ ដែលអាចបង្កការលំបាកក្នុងពេលបំពេញការងារគណៈកម្មការសហគមន៍នេសាទ ក៏ដូចជាការងារទំនាក់ទំនងជាមួយក្រុមការងារផ្សេងៗ ឬភ្ញៀវទេសចរណ៍ជាដើម។ ដូច្នេះ គណៈកម្មការសហគមន៍នេសាទនេះមានផែនការសាងសង់ស្នាក់ការសហគមន៍មានដូចខាងក្រោម៖

| ប្រភេទសកម្មភាព | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ | តម្លៃប៉ាន់ ស្មាន (រៀល) | ប្រភពទុន |
|---|---|---|---|---|
| ផែនការសាងសង់ស្នាក់ការ | ២០២០ | ២០២៣ | ២៨.០០០.០០០ | រាជរដ្ឋាភិបាល អង្គការដៃគូ សប្បុរសជន |
| តុ កៅអី និងទូឯកសារ | ២០២០ | ២០២៣ | ២.០០០.០០០ | |
| សរុប | | | ៣០.០០០.០០០ | |

### គ.១១.ផែនការថវិការទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍

ដោយឡែក គណៈកម្មការសហគមន៍បានដើរតួនាទីសំខាន់ក្នុងការស្វែងរកប្រាក់ចំណូលនិងចំណាយពីប្រភពផ្សេងៗដូចជា៖ ភាគទានពីសមាជិកសហគមន៍ អង្គការដៃគូអភិវឌ្ឍន៍ សប្បុរសជន កន្លែងកំសាន្តធម្មជាតិនិងការធ្វើទស្សនកិច្ចរបស់ភ្ញៀវមកក្នុងសហគមន៍នេសាទ។

ផែនការស្វែងរកថវិការសម្រាប់ទ្រង់សហគមន៍មានក្នុងតារាងខាងក្រោះ

| ប្រភេទប្រាក់ចំណូល | សកម្មភាព | ថ្ងៃខែឆ្នាំ ចាប់ផ្តើម | ថ្ងៃខែឆ្នាំ បញ្ចប់ | ចំណូលសរុប (រៀល) |
|---|---|---|---|---|
| ភាគទានពីសមាជិកសហគមន៍ | ចុះប្រមូលប្រាក់សមាជិកភាព | ២០២០ | ២០២៣ | ១.៥៧៧.៥០០ |
| ភាគទានប្រចាំឆ្នាំ | ចុះប្រមូលប្រាក់ ភាគទានប្រចាំឆ្នាំ | ២០២០ | ២០២៣ | ១.០០០.០០០ |
| ភាគទានពីអ្នកខាងក្រៅ ឬអ្នកមិនមែនជាសមាជិក | ប្រមូលប្រាក់បដិភាគពីអ្នក នេសាទខាងក្រៅ | ២០២០ | ២០២៣ | ២៥០.០០០ |
| | ប្រមូលប្រាក់អ្នកមិនមែនជា សមាជិក | ២០២០ | ២០២៣ | ៥០០,០០០ |
| ភាគទានពីក្រុមសន្សំ | ប្រមូលប្រាក់បដិភាគ ពីក្រុមសន្សំ | ២០២០ | ២០២៣ | ២០០.០០០ |
| សរសេរគម្រោងស្នើសុំៈ<br>-បដិភាគពីរាជរដ្ឋាភិបាល<br>-អំណោយពីសប្បុរសជន<br>-អង្គការដៃគូ | -បញ្ចូលផែនការទៅក្នុងផែន ការអភិវឌ្ឍន៍ឃុំ<br>-សរសេរគម្រោងស្នើសុំពីអង្គ ការដៃគូ | ២០២០ | ២០២៣ | ១.០០០.០០០ |
| សរុប | | | | ៤,៥២៧,៥០០ |

**គ.១២.ផែនការចូលរួមប្រជុំជាមួយស្ថាប័នពាក់ព័ន្ធ**

គណៈកម្មការសហគមន៍ នឹងចូលរួមប្រជុំជាមួយស្ថាប័នពាក់ព័ន្ធ ក្នុងគោលបំណងចែករំលែកព័ត៌មាន និងបទពិសោធន៍ និងមេរៀនដែលបានរៀនសូត្រ ក្នុងការគ្រប់គ្រងនិងការអភិវឌ្ឍន៍សហគមន៍នេសាទក្នុងព្រះរាជាណាចក្រកម្ពុជាសម្រាប់ជាផលប្រយោជន៍រួមរបស់សហគមន៍នេសាទ។

កិច្ចប្រជុំជាមួយស្ថាប័នពាក់ព័ន្ធក្នុងគោលបំណងៈ

- រំលែកព័ត៌មាននិងបទពិសោធន៍ក្នុងការគ្រប់គ្រងនិងការអភិវឌ្ឍន៍សហគមន៍នេសាទ
- បង្កើនការទំនាក់ទំនងល្អជាមួយសហគមន៍និងអ្នកពាក់ព័ន្ធ ។

| លរ | សកម្មភាព | ចំនួន | ថ្ងៃខែឆ្នាំ ចាប់ផ្តើម | ថ្ងៃខែឆ្នាំ បញ្ចប់ |
|---|---|---|---|---|
| ១ | កិច្ចប្រជុំជាមួយស្ថាប័នពាក់ព័ន្ធ | ៤ដង/១ឆ្នាំ | ២០២០ | ២០២៣ |
| ៣ | ប្រជុំប្រចាំខែរបស់គណៈកម្មការសហគមន៍នេសាទ | ១ដង/១ខែ | ២០២០ | ២០២៣ |
| ៤ | ចូលរួមប្រជុំប្រចាំខែជាមួយក្រុមប្រឹក្សាឃុំ | ១ដង/១ខែ | ២០២០ | ២០២៣ |

គ.១៣.ផែនការសុវត្ថិភាពក្នុងការនេសាទលើផ្ទៃសមុទ្រ

ផែនការសុវត្ថិភាពក្នុងការនេសាទលើផ្ទៃសមុទ្រត្រូវរៀបចំឡើងដោយៈ

| លរ | ប្រភេទសម្ភារៈ | ចំនួន | ទីកន្លែង | ថ្ងៃខែឆ្នាំ ចាប់ផ្តើម | ថ្ងៃខែឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|
| ១ | វិទ្យុទាក់ទង | ៣ | នៅតាមសហគមន៍នេសាទព្រែកត្នោត | ៣០/៦/២០២០ | ៣០/៦/២០២៣ |
| ២ | អាវពោង | ១៥ | | | |
| ៣ | ទូកម៉ាស៊ីន | ១ | | | |
| ៤ | ការដុងប្រេង | ២ | | | |
| ៥ | ភ្លើងសញ្ញា | ១កំប្លេ | | | |

## ឃ.យុទ្ធសាស្រ្ត

នៅក្នុងសហគមន៍នេសាទ ត្រូវរៀបចំយុទ្ធសាស្រ្តមួយចំនួន ដើម្បីការអនុវត្តផែនការទទួលបានជោគជ័យ។ យុទ្ធសាស្រ្តទាំងមានដូចខាងក្រោមៈ

- បង្កើតគណៈកម្មការសម្រាប់អនុវត្តតាមដានត្រួតពិនិត្យនិងវាយតម្លៃការអនុវត្តន៍ផែនការរួមមានៈ សមាជិកគណៈកម្មការសហគមន៍នេសាទ ចាស់ទុំ សមាជិកសហគមន៍នេសាទ ដែលមានបទពិសោធន៍ និងចំណេះដឹងល្អជាពិសេសអំពីបញ្ហានេសាទ
- ស្នើសុំជំនួយបច្ចេកទេសពីរដ្ឋបាលជលផលមានសមត្ថកិច្ច ដើម្បីជួយផ្តល់យោបល់ចំពោះផែនការណាដែលទាក់ទង នឹងបច្ចេកទេសជលផលដូចជា ការធ្វើផែនការកន្លែងអភិរក្សត្រីមេពូជ ការរៀបចំកន្លែងអភិរក្សព្រៃលិចទឹក កន្លែងអភិរក្សជីវៈចម្រុះ ការស្តារព្រែក ការកំណត់ឧបករណ៍នេសាទ ការរកថវិកាទ្រទ្រង់ជាដើម
- រៀបចំយុទ្ធសាស្រ្តទំនាក់ទំនងជាមួយស្ថាប័នជំនាញ អង្គការនានា គម្រោងនិងម្ចាស់ជំនួយ ដើម្បីទទួលបានការឧបត្ថម្ភគាំទ្រនិងថវិកាសម្រាប់ដំណើរការអនុវត្តផែនការ
- រៀបចំកម្មវិធីអនុវត្តផែនការតាមដំណាក់កាលនីមួយៗដោយជាក់លាក់
- ទាក់ទងជាមួយរដ្ឋបាលជលផលនិងដៃគូដើម្បីសុំការគាំទ្រថវិកាសំរាប់ទ្រទ្រង់ផែនការគ្រប់គ្រងសហគមន៍
- ផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ដល់សមាជិកសហគមន៍នេសាទនិងអ្នកពាក់ព័ន្ធសំខាន់ៗ ដើម្បីជម្រុញការចូលរួម និងគាំទ្រដល់ការអនុវត្តផែនការគ្រប់គ្រងនេះ
- កៀងគោការចូលរួមចំណែករបស់សមាជិកសហគមន៍នេសាទ
- រៀបចំវិធានការចំពោះអ្នកនេសាទមកពីក្រៅសហគមន៍
- ពង្រឹងសមត្ថភាពបច្ចេកទេសនិងគ្រប់គ្រងរបស់គណៈកម្មការសហគមន៍នេសាទ
- ចងក្រងក្រុមអ្នកនេសាទទៅតាមប្រភេទឧបករណ៍នេសាទ ដើម្បីចូលរួមអនុវត្តផែនការ
- បញ្ចូលផែនការគ្រប់គ្រងសហគមន៍នេសាទទៅក្នុងផែនការអភិវឌ្ឍន៍ឃុំ។

## តារាងសង្ខេបផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ព្រែកត្នោត រយៈពេល ០៣ ឆ្នាំ (ខែមិថុនា ឆ្នាំ២០២០- ខែមិថុនា ឆ្នាំ ២០២៣)

| ប្រភេទផែនការ/សកម្មភាព | លទ្ធផលរំពឹងទុក | ការប៉ាន់ស្មានចំណាយ (រៀល) | ប្រភពជំនួយ | ពេលផ្តើម | ពេលបញ្ចប់ |
|---|---|---|---|---|---|
| ១.ផែនការប្រើប្រាស់ឧបណ៍នេសាទ | • កាត់បន្ថយទំនាស់នេសាទក្នុងកន្លែងនេសាទ<br>• កាត់បន្ថយការប្រើប្រាស់ឧបករណ៍នេសាទល្មើសច្បាប់<br>• សហគមន៍នឹងអនុវត្តន៍ប្រកាសស្តីពីការប្រើប្រាស់ឧបករណ៍ | ១.៥០០.០០០ | | ២០២០ | ២០២៣ |
| ១.១.ប្រជុំផ្សព្វផ្សាយការប្រើប្រាស់ឧបករណ៍នេសាទលក្ខណៈគ្រួសារក្នុង១ឆ្នាំ/២ដង | សមាជិកនឹងយល់ដឹងពីការការប្រើប្រាស់ឧបករណ៍នេសាទលក្ខណៈគ្រួសារ | ១.៥០០.០០០ | អង្គការដៃគូ សប្បុរសជន រដ្ឋាភិបាល | | |
| ១.២.ផ្សព្វផ្សាយដល់អ្នកពាក់ព័ន្ធ | អ្នកពាក់ពន្ធ នឹងចូលរួមផ្សព្វផ្សាយបន្តដល់សហគមន៍ដ៏ទៃ | | | | |
| ១.៣.ត្រួតពិនិត្យ និងតាមដាន | គណៈកម្មការនិងសមាជិកចូលរួមឃ្លាំមើល និងរាយការណ៍ | | | | |
| ២.ផែនការកែលំអរដែននេសាទ | • បង្កើនផលត្រី វារីសត្វគ្រប់ប្រភេទ និងព្រៃលិចទឹក<br>• ជួយថែរក្សាលំនឹងបរិស្ថានធម្មជាតិ<br>• មានភ្ញៀវទេសចរណ៍និងផ្តល់ការងារដល់សហគមន៍<br>• សហគមន៍មានដើមទុនសម្រាប់ខ្លួនឯង | | | | |
| ២.១.ផែនការដាំព្រៃកោងកាងនៅកន្លែងខោសតាពូ ដែលមានទំហំ ២,៥ ហត | • ផ្សព្វផ្សាយដល់អ្នកពាកព័ន្ធទាំងអស់<br>• ការដាំកូនព្រៃកោងកាង | ២.០០០.០០០ | អង្គការដៃគូ សប្បុរសជន រដ្ឋាភិបាល | ២០២០ | ២០២៣ |
| ៣.ការរៀបចំកន្លែងអភិរក្ស | •ប្រភេទត្រីមេពូជ និងវារីសត្វគ្រប់ប្រភេទត្រូវបានធ្វើការអភិរក្ស<br>•ប្រភេទព្រៃលិចទឹកនឹងត្រូវបានការពារ<br>•ប្រជាជននឹងយល់ដឹងពីសារៈសំខាន់កន្លែងអភិរក្សនឹងចូលរួមថែរក្សា | | | | |
| ៣.១ បោះបង្គោលស៊ីម៉ង់កន្លែងអភិរក្សព្រែកក្តាម និងថ្មបីដុំ | ចំនួន២០ បង្គោលនឹងបានបោះនៅកន្លែងអភិរក្សវាលភក់ក្រែមឈាមនិងខោសទុង ដោយមានផែនទីសំគាល់កន្លែងអភិរក្ស | ១០.៥០០.០០០ | អង្គការដៃគូ | ២០២០ | ២០២៣ |
| ៣.២ ផ្សព្វផ្សាយដល់ប្រជាជន | ប្រជាជននឹងយល់ដឹងពីសារៈប្រយោជន៍កន្លែងអភិរក្ស | ២០០.០០០ | អង្គការដៃគូ សប្បុរសជន រដ្ឋាភិបាល | ២០២០ | ២០២៣ |
| ៣.៣ ប្រអប់សិប្បនិមិត្ត២០ដាក់នៅព្រែកក្តាមនិងថ្មបីដុំ | ចំនួន២០ ប្រអប់សិប្បនិមិត្តនឹងដាក់នៅព្រែកក្តាមនិងថ្មបីដុំ | ១០.២០០.០០០ | | | |
| ៣.៤ សង់រោងយាម | រោងយាមចំនួន០១ត្រូវបានសាងសងនៅកន្លែងអភិរក្សទំហំ ៤មx៥ម | ១.៨០០.០០០ | | | |
| ៣.៥ ចុះល្បាតជាប្រចាំ | បទល្មើសនេសាទនឹងថយចុះតាមរយៈការចុះល្បាត | ១.០៨០.០០០ | | | |
| ៤.ការគ្រប់គ្រងព្រៃកោងកាងសហគមន៍នេសាទ | • សមាជិកសហគមន៍យល់ដឹងពីសារៈសំខាន់នៃនាទីព្រៃលិចទឹក | | | | |

| | | | | | |
|---|---|---|---|---|---|
| | • ព្រៃលិចទឹកត្រូវបានការពារដោយសមាជិកសហគមន៍នេសាទ | | | | |
| ៤.១ ប្រជុំផ្សព្វផ្សាយពីសារៈប្រយោជន៍ព្រៃកោងកាង | សមាជិកសហគមន៍យល់ដឹងពីសារៈប្រយោជន៍ព្រៃលិចទឹក | ២០០.០០០ | រដ្ឋាភិបាល អង្គការដៃគូ សប្បុរសជន | ២០២០ | ២០២៣ |
| ៤.២.ដាំព្រៃលិចទឹកនៅដាំព្រៃកោងកាងនៅខេសទំពូ ដែលមានទំហំ២,៥ ហត | រៀបចំថ្នាលកូនឈើ ពីធីដាំកូនឈើ និងដាក់ស្លាកសញ្ញាការពារ ថែរក្សា ការពារ | ២.០០០.០០០ | | | |
| ៤.៣.ថែរក្សា និងការពារព្រៃកោងកាង | ផ្សព្វផ្សាយដល់អ្នកពាក់ព័ន្ធទាំងអស់ និងដាក់ស្លាកសញ្ញាការពារ | ៨០០.០០០ | | | |
| ៤.៤ ចុះល្បាតជាប្រចាំ | សកម្មភាពកាប់បផ្លាញ់ព្រៃលិចទឹកនឹងត្រូវបានទប់ស្កាត់ | ១.០០០.០០០ | | | |
| **៥.ការអភិវឌ្ឍន៍វារីវប្បកម្ម** | • បង្កើនត្រីសាច់សម្រាប់ហូបចុកក្នុងមូលដ្ឋាន<br>• រកប្រាក់ចំណូលជួយស្ទួយសេដ្ឋកិច្ចគ្រួសារ<br>• កាត់បន្ថយសម្ពាធនេសាទលើធនធានជលផលហូសកំរិត។ | | | | |
| **៥.១.ចិញ្ចឹមត្រីឆ្តងតាមបច្ចេកទេសជាលក្ខណៈគ្រួសារក្នុងបែ ចំនួន ២០គ្រួសារ** | | **១១.០០០.០០០** | | | |
| ៥.១.១.ជ្រើសរើសសមាជិកសហគមន៍ | សមាជិកសហគមន៍ចំនួន៦ គ្រួសារត្រូវបានជ្រើសរើស | ៥.០០០.០០០ | សប្បុរសជន រដ្ឋាភិបាល | ២០២០ | ២០២៣ |
| ៥.១.២ បណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមត្រីឆ្តង | ចំនួន៦ គ្រួសារ នឹងត្រូវបានបណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមត្រីឆ្តង | | | | |
| ៥.១.៣ ធ្វើបែចិញ្ចឹមត្រីឆ្តង | ចំនួន៦ បែ ដែលក្នុង១បែមានទំហំ៥ម x ៣មx ២,៥ម ត្រូវបានសាងសង់ | | | | |
| ៥.១.៤ ការដាក់កូនត្រីក្នុងបែ | ចំនួនកូនត្រី ៣០០ កូននឹងត្រូវបានផ្តល់ក្នុងមួយគ្រួសារ | | | | |
| ៥.១.៥ ត្រួតពិនិត្យតាមដាន | សមាជិកសហគមន៍ចំនួន ៦ គ្រួសារ នឹងត្រូវបានធ្វើការត្រួតពិនិត្យ | | | | |
| **៥.២.ចិញ្ចឹមត្រីតក់កែតាមបច្ចេកទេសជាលក្ខណៈគ្រួសារតាមបែចំនួន៦គ្រួសារ** | | | | | |
| ៥.២.១.ជ្រើសរើសសមាជិកសហគមន៍ | សមាជិកសហគមន៍ចំនួន៦ គ្រួសារត្រូវបានជ្រើសរើស | ៣.០០០.០០០ | សប្បុរសជន រដ្ឋាភិបាល | ២០២០ | ២០២៣ |
| ៥.២.២ បណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមត្រីតក់កែ | ចំនួន៦ គ្រួសារ នឹងត្រូវបានបណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមត្រីតក់កែ | | | | |
| ៥.២.៣ ធ្វើបែចិញ្ចឹមត្រីតក់កែ | ចំនួន៦ បែ ដែលក្នុង១បែមានទំហំ ៥ម x ៣មx ២,៥ម ត្រូវបានសាងសង់ | | | | |
| ៥.២.៤ ការដាក់កូនត្រីក្នុងបែ | ចំនួនកូនត្រី៣០០ កូននឹងត្រូវបានផ្តល់ក្នុងមួយគ្រួសារ | | | | |
| ៥.២.៥ ត្រួតពិនិត្យតាមដាន | សមាជិកសហគមន៍ចំនួន៦គ្រួសារ នឹងត្រូវបានធ្វើការត្រួតពិនិត្យ | | | | |
| **៥.៣.ចិញ្ចឹម គ្រែងឈាមតាមបច្ចេកទេសជាលក្ខណៈគ្រួសារ ទំហំ ២ហត** | | | | | |
| ៥.៣.១ ជ្រើសរើសសមាជិកសហគមន៍ | សមាជិកសហគមន៍ចំនួន២០ គ្រួសារចូលរួមដោយស្ម័គ្រចិត្ត | ២.៥០០.០០០ | | ២០២០ | ២០២៣ |
| ៥.៣.២ បណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹម | ចំនួន ២០ គ្រួសារ នឹងត្រូវបានបណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមគ្រែងឈាម | | | | |
| ៥.៣.៣ រៀបចំកន្លែងចិញ្ចឹមគ្រែងឈាម | ទំហំ ២ហត ត្រូវបានរៀបចំ | | | | |

| | | | | | |
|---|---|---|---|---|---|
| ៥.៣.៤ ការដាក់កូនគ្រែងឈាម | ចំនួនកូនគ្រែងឈាម ១២០០គក នឹងត្រូវបានផ្តល់ក្នុង២០គ្រួសារ | | | | |
| ៥.៣.៥ ត្រួតពិនិត្យតាមដាន | សមាជិកសហគមន៍ចំនួន៦គ្រួសារ នឹងត្រូវបានធ្វើការត្រួតពិនិត្យ | | | | |
| **៥.៤.ធនាគារក្តាមសេះតាមបច្ចេកទេសជាលក្ខណៈគ្រួសារ** | • សមាជិកសហគមន៍បង្កើនប្រាក់ចំណូល<br>• សមាជិកយល់ដឹងពីបច្ចេកទេសចិញ្ចឹមក្តាមសេះ | | | | |
| ៥.១.ផ្សព្វផ្សាយទស្សនៈទានដល់សហគមន៍ | ទស្សនៈទានត្រូវបានផ្សព្វផ្សាយដល់សហគមន៍ | ៦.០០០.០០០ | សប្បុរសជន រដ្ឋាភិបាល | ២០២០ | ២០២៣ |
| ៥.២.ការរៀបចំក្រុម | ចំនួន បីក្រុម ត្រូវបានរៀបចំ | | | | |
| ៥.៣.បោះឆ្នោតជ្រើសរើសប្រធាន លេខា និងហិរញ្ញឹក | ការរៀបចំបោះឆ្នោតជ្រើសរើសប្រធាន លេខា និងហិរញ្ញឹក | | | | |
| ៥.៤.បង្កើតគោលការណ៍ និងបទបញ្ជាផ្ទៃក្នុង | បង្កើតគោលការណ៍ និងបទបញ្ជាផ្ទៃក្នុង | | | | |
| ៥.៥.ផ្តល់ទុន | ទុនត្រូវបានផ្តល់ | | | | |
| ៦.៦.បណ្តុះបណ្តាលពីការរៀបឯកសារ និងថវិកា | បណ្តុះបណ្តាលក្រុមធនាគារក្តាមសេះពីការរៀបឯកសារនិងថវិកា | | | | |
| ៥.៧.ត្រួតពិនិត្យតាមដាន | ក្រុមធនាគារក្តាមសេះត្រូវបានត្រួតពិនិត្យ និងតាមដាន | | | | |
| **៦. ផែនការអភិវឌ្ឍន៍មុខរបរទ្រទ្រង់ជីវភាព** | | | | | |
| **៦.១.ការចិញ្ចឹមមាន់តាមបច្ចេកទេសជាលក្ខណៈគ្រួសារ** | **ការចិញ្ចឹមមាន់តាមបច្ចេកទេសជាលក្ខណៈគ្រួសារ** | | | | |
| ៦.១.១.ជ្រើសរើសកសិករស្ម័គ្រចិត្ត | កសិករស្ម័គ្រចិត្តចំនួន១០ គ្រួសារត្រូវបានជ្រើសរើស | ៣.៥០០.០០០ | | ២០២០ | ២០២៣ |
| ៦.១.២.បណ្តុះបណ្តាលចិញ្ចឹមជ្រូក | បច្ចេកទេសចិញ្ចឹមជ្រូកត្រូវបានបណ្តុះបណ្តាលចំនួន ១០ គ្រួសារ | | | | |
| ៦.១.៣.ជ្រើសរើសនិងធ្វើទ្រុង | ការជ្រើសរើសនិងធ្វើទ្រុងសម្រាប់ចំនួន ១០ គ្រួសារ | | | | |
| ៦.១.៤.ផ្តល់ពូជនិងដាក់ពូជចិញ្ចឹម | ចំនួន ០៦ ក្បាល ផ្តល់ពូជសម្រាប់គ្រួសារនីមួយៗ | | | | |
| ៦.១.៤.តាមដានត្រួតពិនិត្យ | ចំនួន ១០ គ្រួសារ ត្រូវបានតាមដានត្រួតពិនិត្យ | | | | |
| **៧.ផែនការអភិវឌ្ឍន៍កន្លែងកំសាន្តរបស់សហគមន៍** | • បង្កើនប្រាក់ចំណូលដែលជួយស្ទួយសេដ្ឋកិច្ចគ្រួសារ<br>• កាត់បន្ថយសម្ពាធអាជីវកម្មលើធនធានជលផលហួសកំរិត និង<br>• ដើម្បីឱ្យសហគមន៍មានដើមទុនសម្រាប់អនុវត្តការងារដោយខ្លួន | | | | |
| ៧.១.ផ្សព្វផ្សាយទស្សនៈដល់សមាជិកសហគមន៍ | ទស្សនៈទាននឹងផ្សព្វផ្សាយដល់សមាជិកសហគមន៍ | ១១.៣៦០.០០០ | | ២០២០ | ២០២៣ |
| ៧.២.បង្កើតក្រុមសម្រាប់អនុវត្ត | ក្រុមរៀបចំកន្លែងកំសាន្តសហគមន៍នឹងត្រូវបានបង្កើត | | | | |
| ៧.៣.រៀបចំគោលការណ៍ និងបទបញ្ជាផ្ទៃក្នុង | គោលការណ៍ និងបទបញ្ជាផ្ទៃក្នុងនឹងត្រូវបានរៀបចំ | | | | |
| ៧.៤.បណ្តុះបណ្តាលពីការរៀបចំឯកសារនិងថវិកា | ឯកសារន ថវិកានឹងបានបណ្តុះបណ្តាល | | | | |
| ៧.៥.ត្រួតពិនិត្យតាមដាន | ក្រុមរៀបចំកន្លែងកំសាន្តនឹងធ្វើការត្រួតពិនិត្យនិងកែលម្អ | | | | |
| **៨.ការពង្រឹងសមត្ថភាពគណៈកម្មការសហគមន៍នេសាទ** | • គណៈកម្មការនឹងអាចអនុវត្តសកម្មភាពក្នុងការងារ<br>• យល់ពីតួនាទីនិងភារកិច្ចរបស់ពួកគាត់ និង | | | | |

| | | | | | |
|---|---|---|---|---|---|
| | • បង្កើនសាមគ្គីភាពនិងការទំនាក់ទំនងល្អជាមួយអ្នកពាក់ព័ន្ធ | | | | |
| ៨.១.បណ្តុះបណ្តាលរបៀបធ្វើកំណត់ហេតុ សរសេររបាយការណ៍ និងលិខិតរដ្ឋបាល | កំណត់ហេតុ សរសេររបាយការណ៍ និងលិខិតរដ្ឋបាល នឹងត្រូវបាន បណ្តុះបណ្តាល | ៤០០.០០០ | រដ្ឋាភិបាល អង្គការដៃគូ សប្បុរសជន | ២០២០ | ២០២៣ |
| ៨.២.បណ្តុះបណ្តាលការគ្រប់គ្រងថវិកា | ការគ្រប់គ្រងថវិកា នឹងត្រូវបានបណ្តុះបណ្តាល | ៣០០.០០០ | | ២០២០ | ២០២៣ |
| ៨.៣.បណ្តុះបណ្តាលការដោះស្រាយទំនាស់ | វិធីសាស្ត្រដោះស្រាយទំនាស់នឹងត្រូវបានបណ្តុះបណ្តាល | ៤០០.០០០ | | ២០២០ | ២០២៣ |
| ៨.៤.បណ្តុះបណ្តាលជំនាញក្នុងការសម្របសម្រួល | ជំនាញសម្របសម្រួលនឹងត្រូវបានបណ្តុះបណ្តាល | ២០០.០០០ | | ២០២០ | ២០២៣ |
| ៨.៥.បណ្តុះបណ្តាលការរៀបចំផែនការ | ការរៀបចំផែនការ នឹងត្រូវបានបណ្តុះបណ្តាល | ៤០០.០០០ | | ២០២០ | ២០២៣ |
| ៩.ផ្សព្វផ្សាយពីច្បាប់ជលផល និងលិខិតបទដ្ឋានពាក់ព័ន្ធ និងកសាងសមត្ថភាពគណៈកម្មការ | • បង្កើនការយល់ដឹងដល់ប្រជាពលរដ្ឋ<br>• កាត់បន្ថយសកម្មភាពបទល្មើសនេសាទ | | | | |
| ៩.១.ផ្សព្វផ្សាយពីច្បាប់ជលផលនិងលិខិតបទដ្ឋានពាក់ព័ន្ធ | សមាជិកសហគមន៍ នឹង ផ្សព្វផ្សាយពីច្បាប់ជលផលនិងលិខិតបទដ្ឋាន | ២.០០០.០០០ | រដ្ឋាភិបាល អង្គការដៃគូ | ២០២០ | ២០២៣ |
| ៩.២.ផ្សព្វផ្សាយលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុង | សមាជិកសហគមន៍នឹងត្រូវបានផ្សព្វផ្សាយលក្ខន្តិកៈ និងបបញ្ជាផ្ទៃក្នុង | ៧៥០.០០០ | | | |
| ១០.ផែនការបង្កើតស្នាក់ការសហគមន៍នេសាទ | | | | | |
| ១០.១.បង្កើតស្នាក់ការ | ស្នាក់ការរបស់សហគមន៍នឹងត្រូវបានជួសជុល | ១៥.០០០.០០០ | រដ្ឋាភិបាល អង្គការដៃគូ សប្បុរសជន | ២០២០ | ២០២៣ |
| ១០.២.បំពាក់សម្ភារៈ | សម្ភារៈកៅអី និងទូឯកសានឹងត្រូវបានបំពាក់ | | | | |
| ១០.៣.គម្រោងសាងសង់បណ្ណាល័យ | បណ្ណាល័យនឹងត្រូវបានសាងសង់ | ៧.៨០០.០០០ | | | |
| ១១. ផែនការថវិកាសម្រាប់ទ្រទ្រង់សហគមន៍នេសាទ | | | | | |
| ១១.១.ភាគប្រចាំឆ្នាំពីសមាជិកសហគមន៍ | ភាគប្រចាំឆ្នាំពីសមាជិកសហគមន៍ | ១.៣៣៧.៥០០ | រដ្ឋាភិបាល អង្គការដៃគូ សប្បុរសជន | ២០២០ | ២០២៣ |
| ១១.២.ពីអ្នកនេសាទខាងក្រៅឬអ្នកមិនមែនជាសមាជិក | ពីអ្នកនេសាទខាងក្រៅឬអ្នកមិនមែនជាសមាជិក | ៨.២៥០.០០០ | | | |
| ១១.៣. អំណោយពីសប្បុរសជន និងអង្គការដៃគូ | សប្បុរសជន និងអង្គការដៃគូអភិវឌ្ឍន៍ | ៤.០០០.០០០ | | | |
| ១១.៤.ក្រុមប្រឹក្សាឃុំ | មូលនិធិរបស់ឃុំ | ៧៥០.០០០ | | | |
| ១២.ផែនការចូលរួមប្រជុំជាមួយស្ថាប័នពាក់ព័ន្ធ | | | | | |
| ១.កិច្ចប្រជុំជាមួយស្ថាប័នពាក់ព័ន្ធ | គណៈកម្មការ នឹងចូលរួមប្រជុំជាមួយស្ថាប័នពាក់ព័ន្ធ | ៨០.០០០ | រដ្ឋាភិបាល អង្គការដៃគូ សប្បុរសជន | ២០២០ | ២០២៣ |
| ២.ប្រជុំប្រចាំខែរបស់គណៈកម្មការសហគមន៍នេសាទ | ប្រជុំប្រចាំខែរបស់គណៈកម្មការសហគមន៍នេសាទត្រូវបានរៀបចំ | ៨០.០០០ | | | |
| ៣.ចូលរួមប្រជុំប្រចាំខែជាមួយអ្នកពាក់ព័ន្ធ | គណៈកម្មការសហគមន៍នេសាទនឹងចូលរួមប្រជុំ ប្រចាំខែជាមួយអ្នកពាក់ព័ន្ធ | ២០០.០០០ | | | |
| ១៣.ផែនការសុវត្ថិភាពក្នុងការនេសាទលើផ្ទៃសមុទ្រ | | | | | |
| ១៣.១.ទូកម៉ាស៊ីន | ទូកម៉ាស៊ីនចំនួន០១គ្រឿង | ៣.០០០.០០០ | អង្គការដៃគូ សប្បុរសជន | ២០២០ | ២០២៣ |
| ១៣.២.សម្ភារៈ និងមធ្យោបាយ | វិទ្យុទាក់ទង អាវពោង ការដុងប្រេង និងភ្លើងសញ្ញា | ២.៥០០.០០០ | | | |

**តារាងកម្មវិធីការងារសម្រាប់សហគមន៍នេសាទព្រែកត្នោត រយៈពេល ០៣ ឆ្នាំ (ខែមិថុនា ឆ្នាំ២០២០- ខែមិថុនា ឆ្នាំ ២០២៣)**

| សកម្មភាព | ២០២០ | | | | | | | ២០២១ | | | | | | | | | | | | ២០២២ | | | | | | | | | | | | ២០២៣ | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ខែនីមួយៗ | | | | | | | ខែនីមួយៗ | | | | | | | | | | | | ខែនីមួយៗ | | | | | | | | | | | | ខែនីមួយៗ | | | | | |
| | 6 | 7 | 8 | 9 | 10 | 11 | 12 | 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | 11 | 12 | 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | 11 | 12 | 1 | 2 | 3 | 4 | 5 | 6 |
| ១.ផែនការប្រើប្រាស់ឧបករណ៍នេសាទ | → | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ២.ផែនការកែលំអរដែននេសាទ | → | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ៣.ផែនការកំណត់ និងរៀបចំកន្លែងអភិរក្ស | → | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ៤.ផែនការគ្រប់គ្រងព្រៃកោងកាង | → | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ៥.ផែនការអភិវឌ្ឍន៍វារីវប្បកម្ម | → | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ៦.ផែនការអភិវឌ្ឍន៍មុខរបរទ្រទ្រង់ជីវភាព | → | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ៧.ផែនការអភិវឌ្ឍន៍កន្លែងកំសាន្តរបស់សហគមន៍ | → | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ៨.ការពង្រឹងសមត្ថភាពគណៈកម្មការសហគមន៍នេសាទ | → | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ៩.ផែនការផ្សព្វផ្សាយពីច្បាប់ជលផល និងលិខិតបទដ្ឋាន | → | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ១០.ផែនការបង្កើតស្នាក់ការ និងបណ្ណាល័យសហគមន៍ | → | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ១១.ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍ | → | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ១២.ផែនការចូលរួមប្រជុំជាមួយស្ថាប័នពាក់ព័ន្ធ | → | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ១៣.ផែនការសុវត្ថិភាពក្នុងការនេសាទលើផ្ទៃសមុទ្រ | → | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |

សូមគោរពជូន
លោកមេឃុំព្រែកត្នោត
ដើម្បីជូនពិនិត្យ និងសម្រួល
ថ្ងៃ..........ខែជេស្ឋឆ្នាំជូត ទោស័ក ព.ស ២៥៦៤
..................ថ្ងៃទី១៧.....ខែមិថុនា ឆ្នាំ២០២០
**ប្រធានគណៈកម្មការសហគមន៍នេសាទព្រែកត្នោត**

លេខៈ 659/020
បានឃើញ និង គោរពជូន
លោកនាយសង្កាត់រដ្ឋបាលជលផល
ក្បាលមោស
ដើម្បីជូនពិនិត្យ និងសម្រួល
ថ្ងៃ..........ខែជេស្ឋ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤
ថ្ងៃទី១៧.....ខែមិថុនា ឆ្នាំ២០២០
**មេឃុំ**

ជួន ធី

បានឃើញ និង គោរពជូន
លោកនាយផ្នែករដ្ឋបាលជលផលព្រែកត្នោត
ដើម្បីជូនពិនិត្យ និងសម្រួល
ថ្ងៃ..........ខែជេស្ឋឆ្នាំជូត ទោស័ក ព.ស ២៥៦៤
ថ្ងៃទី............ខែមិថុនា ឆ្នាំ២០២០
**នាយសង្កាត់រដ្ឋបាលជលផលក្បាលមោស**

បានឃើញ និង គោរពជូន
លោកនាយខណ្ឌរដ្ឋបាលជលផលកំពត
ដើម្បីជូនពិនិត្យ និងសម្រួល
ថ្ងៃ..........ខែជេស្ឋឆ្នាំជូត ទោស័ក ព.ស ២៥៦៤
ថ្ងៃទី១៨.......ខែមិថុនា ឆ្នាំ២០២០
**នាយផ្នែករដ្ឋបាលជលផលព្រែកត្នោត**

អ៊ុន. ចាំ

លេខៈ..........
បានឃើញ និង គោរពជូន
លោកប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តកំពត
ដើម្បីជូនពិនិត្យ និងសម្រួល
ថ្ងៃ..........ខែ..........ឆ្នាំជូត ទោស័ក ព.ស ២៥៦៤
..........ថ្ងៃទី.........ខែ..........ឆ្នាំ ២០២០
**នាយខណ្ឌរដ្ឋបាលជលផលកំពត**

ស សុរិន

លេខ..........
បានឃើញ និង គោរពជូន
ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា ប្រធានរដ្ឋបាលជលផល
ដើម្បីពិនិត្យ និង សម្រេចដោយអនុគ្រោះ
ថ្ងៃ..........ខែ..........ឆ្នាំជូត ទោស័ក ព.ស ២៥៦៤
..........ថ្ងៃទី.........ខែ..........ឆ្នាំ ២០២០
**ប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តកំពត**

ចាន់ រិទ្ធិ

លេខ..........
បានឃើញ និងឯកភាព
ថ្ងៃ..........ខែ..........ឆ្នាំជូត ទោស័ក ព.ស ២៥៦៤
រាជធានីភ្នំពេញ .ថ្ងៃទី.........ខែ..........ឆ្នាំ២០២០
**ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា ប្រធានរដ្ឋបាលជលផល**

អេង ជាសាន